ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Ministry of Agriculture, Forestry and Fisheries


# យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា
# (២០១១-២០២០)

# Strategy for Natural Rubber Development in Cambodia
# (2011-2020)










អគ្គនាយកដ្ឋានកៅស៊ូ

General Directorate of Rubber

ខែ សីហា ឆ្នាំ២០១១

August 2011

# អារម្ភកថា

កៅស៊ូធម្មជាតិ គឺជាដំណាំសេដ្ឋកិច្ចមួយប្រភេទ ដែលផ្តល់នូវពហុប្រយោជន៍ជាច្រើនដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ និងដល់សង្គមទាំងមូល ជាពិសេសបានផ្តល់នូវប្រាក់ចំណូល សម្រាប់បង្កើននូវជីវភាពរស់នៅ ការបង្កើតការងារនៅតាមមូលដ្ឋានជនបទ និងបានរួមចំណែកដល់ការកាត់បន្ថយនូវការកើនឡើងកម្តៅជាសាកល និងការប្រែប្រួលអាកាសធាតុផងដែរ ។

ចាប់តាំងពីឆ្នាំ១៩១០ដែលជាកាលបរិច្ឆេទនៃការដាំដុះកៅស៊ូជាលើកដំបូងរហូតមកដល់បច្ចុប្បន្ននេះ ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាមានការវិវត្តន៍ប្រែប្រួលឡើងចុះៗ ទៅតាមរបបនយោបាយរបស់ប្រទេសជាតិ ។ ក្រោយថ្ងៃជ័យជំនះ ៧ មករា ឆ្នាំ១៩៧៩ ឧស្សាហកម្មកៅស៊ូធម្មជាតិបានចាប់ដំណើរការស្តារ និងអភិវឌ្ឍប្រកបដោយលទ្ធផលជាវិជ្ជមាន ។ រហូតមកដល់បច្ចុប្បន្ន ជាពិសេស ចាប់តាំងពីឆ្នាំ១៩៩៩មក បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយឯកជនភាវូបនីយកម្ម អតីតចម្ការកៅស៊ូរដ្ឋទាំង៧ត្រូវបានរៀបចំដាក់ឲ្យធ្វើអវិនិយោគ ដោយប្រែក្លាយទៅជាសហគ្រាសសាធារណៈមានលក្ខណៈសេដ្ឋកិច្ច និងបន្ទាប់មកការផ្ទេរអតីតចម្ការកៅស៊ូរដ្ឋទាំង៧ ទៅឲ្យផ្នែកឯកជនគ្រប់គ្រងទាំងស្រុងក្នុងអំឡុងឆ្នាំ២០០៨-២០០៩ ។ ទន្ទឹមនឹងការធ្វើឯកជនភាវូបនីយកម្មអតីតចម្ការកៅស៊ូរដ្ឋ ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាបានចាប់ផ្តើមបង្កើនសន្ទុះឆ្ពោះទៅរកការអភិវឌ្ឍមួយប្រកបដោយថាមភាព នៅក្នុងការដាំដុះ និងការប្រមូលផល ។ ក្នុងផ្នែកទាំងបីនៃឧស្សាហកម្មកៅស៊ូ រួមមាន ចម្ការកៅស៊ូឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) ចម្ការកៅស៊ូកសិឧស្សាហកម្មនៅលើដីសម្បទានសេដ្ឋកិច្ច (ដែលរាជរដ្ឋាភិបាលបានផ្តល់ទៅឲ្យវិនិយោគិនបរទេស និងក្នុងស្រុក) និងចម្ការកៅស៊ូគ្រួសារឯកជនតូចតាច និងមធ្យម បានដំណើរការអភិវឌ្ឍយ៉ាងសកម្ម និងដោយព្រមៗគ្នា ។ តាមស្ថិតិផ្លូវការរបស់អគ្គនាយកដ្ឋានកៅស៊ូបានបង្ហាញថាផ្ទៃដីកៅស៊ូសរុបនៅទូទាំងប្រទេសក្នុងឆ្នាំ២០១០កន្លងទៅនេះមានចំនួន១៨១.៥០០ហិកតា ក្នុងនោះផ្ទៃដីកៅស៊ូឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ)មានចំនួន៤៦.៨៤៤ហិកតា ផ្ទៃដីកៅស៊ូកសិឧស្សាហកម្ម (ដីសម្បទានសេដ្ឋកិច្ច)មានចំនួន៥៣.០៧៦ហិកតា និងផ្ទៃដីកៅស៊ូគ្រួសារតូចតាច និងមធ្យមមានចំនួន៨១.៥៨០ហិកតា ។

ជាការពិត កំណើននៃការអភិវឌ្ឍវិស័យកៅស៊ូដ៏មានសក្តានុពលនេះ គឺអាស្រ័យទៅលើកត្តាជាច្រើន ដែលបានផ្តល់នូវភាពអនុគ្រោះដល់ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា រួមមាន៖ (១) ប្រទេសកម្ពុជាបានទទួលសុខសន្តិភាព សុវត្ថិភាពល្អប្រសើរ ក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុត និងប្រកបដោយគតិបណ្ឌិតខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ (២) រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយសេរីភាវូបនីយកម្មផ្នែកសេដ្ឋកិច្ច សំដៅជំរុញការធ្វើវិនិយោគលើគ្រប់វិស័យ និងយុទ្ធសាស្ត្រចតុកោណ ជាពិសេសគោលនយោបាយលើកទឹកចិត្តដល់កសិករក្នុងការចូលរួមដាំដុះកៅស៊ូលើដីចម្ការរបស់ខ្លួន ។ (៣) និន្នាការនៃតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិកាន់តែឡើងខ្ពស់ ដោយសារតម្រូវការប្រើប្រាស់កៅស៊ូធម្មជាតិក្នុងពិភពលោកកាន់តែមានបរិមាណច្រើនឡើង ជាមួយនឹងការផ្គត់ផ្គង់នៅដដែល ឬលើសបន្តិចបន្តួចប៉ុណ្ណោះ ។ (៤) កម្ពុជានៅតែមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍកៅស៊ូ ទាំងនៅក្នុងតំបន់ប្រពៃណី (ដែលសម្បូរទៅដោយដីក្រហម) ក៏ដូចជានៅក្នុងតំបន់មិនមែនប្រពៃណី (រួមមានដីប្រផេះ ដីខ្មៅ ឬដីល្បាយខ្សាច់) ដែលស្ថិតនៅភាគខាងលិច ខាងជើង និងភាគឦសាននៃប្រទេស ។

ដូច្នេះ នៅក្នុងតំណាក់កាលនៃការអភិវឌ្ឍដ៏សំខាន់នេះ ដំណាំកៅស៊ូកម្ពុជាបានប្រឈមនូវបញ្ហាមួយចំនួន ដែលការដោះស្រាយបញ្ហាទាំងនោះនឹងផ្អែកទៅលើសារៈសំខាន់មួយផ្នែកធំ នៃលទ្ធផលសម្រាប់ជាផលប្រយោជន៍ចំពោះសេដ្ឋកិច្ចជាតិ



នោះគឺ៖(១)គុណភាពនៃការដាំដុះកៅស៊ូគ្រួសារ និងលទ្ធភាពនៃការទទួលបាននូវវត្ថុសម្ភារប្រកបដោយគុណភាព ។ (២) ភាពងាយស្រួលនៃលទ្ធភាពទទួលបានសក្តានុពលដីទំនេរសម្រាប់ដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ ។ (៣) ជំរុញការដាំដុះ និងពង្រីកចម្ការកៅស៊ូឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅជុំវិញ តាមអនុក្រឹត្យលេខ៣៦ អនក្រ.បក.ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) ។ (៤) ការបង្កើនខ្សែចង្វាក់តម្លៃ តាមរយៈ ការកែលម្អគុណភាព ការរៀបចំបរិបទនីហរណកម្ម និងការបណ្តុះបណ្តាលតួអង្គកៅស៊ូ ។

ទោះជាយ៉ាងណា លក្ខខណ្ឌប្រមូលផ្តុំដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមសំខាន់ៗ ដែលឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាបានជួបប្រទះ នោះគឺបានរៀបរាប់នៅក្នុងយុទ្ធសាស្ត្រនៃការអភិវឌ្ឍដំណាំកៅស៊ូ ជាពិសេស ការពង្រឹងសមត្ថភាពស្ថាប័ន ការកំណត់បេសកកម្មនៃអគ្គនាយកដ្ឋានកៅស៊ូ និងការរៀបចំក្របខណ្ឌបទបញ្ញត្តិច្បាប់នៃវិស័យកៅស៊ូ ដែលជាមូលដ្ឋានគ្រឹះនៃការអនុវត្តយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះឲ្យទទួលបានជោគជ័យតាមការរំពឹងទុក ។

យើងមានជំនឿយ៉ាងមុតមាំថា ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា ពិតជានឹងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធ ទាំងអស់ក្នុងការលើកស្ទួយវិស័យនេះដើម្បីបម្រើដល់សេដ្ឋកិច្ច និងសង្គម និងការកាត់បន្ថយភាពក្រីក្រនៅជនបទ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១១*

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ចាន់ សារុន



# មាតិកា


**អារម្ភកថា** ............ ១
**មាតិកា** ............ ៣
**១. សេចក្តីផ្តើម** ............ ៥
១.១ សាវតា ............ ៥
១.២ ស្ថានភាពចម្ការកៅស៊ូបច្ចុប្បន្ន ការវិវត្តន៍ និងសក្តានុពលសម្រាប់រយៈពេលវែង ............ ៦
១.៣ ការកែច្នៃជ័រកៅស៊ូ ............ ៩
១.៤ ការធ្វើពាណិជ្ជកម្ម ............ ១០
១.៥ ក្របខណ្ឌច្បាប់ ............ ១១
១.៦ ក្របខណ្ឌស្ថាប័ន ............ ១២
១.៧ លក្ខណៈសម្បត្តិនៃការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជា ............ ១៣
១.៨ ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងហានិភ័យ ............ ១៤
១.៩ បញ្ហាប្រឈម ............ ១៥
១.១០ សកម្មភាពជាអាទិភាព ............ ១៦
*ក- ការត្រួតពិនិត្យ និងការធ្វើវិញ្ញាបនកម្មច្បារពូជ* ............ ១៦
*ខ- ច្បាប់ស្តីពីកៅស៊ូ* ............ ១៦
*គ- ផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូ និងការរៀបចំគម្រោងថវិកា* ១៧
*ឃ- ការអនុវត្តផែនការសកម្មភាព និងការគិតគូរដល់គោលដៅយុទ្ធសាស្ត្រ....* ១៧
*ង- ការសិក្សាអំពីហិរញ្ញប្បទាន និងសកម្មភាពជួយទ្រទ្រង់អគ្គនាយកដ្ឋានកៅស៊ូ* ១៨
**២. ចក្ខុវិស័យ** ............ ១៩
**៣. បេសកកម្ម** ............ ១៩
**៤. គោលបំណង និងគោលដៅ** ............ ១៩
**៥. ក្របខណ្ឌយុទ្ធសាស្ត្រ** ............ ២០
*៥.១ យុទ្ធសាស្ត្រទី១ ៖ ការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ......* ២២
៥.១.១ គោលបំណង ............ ២២
៥.១.២ បញ្ហាប្រឈម ............ ២២
៥.១.៣ សកម្មភាពជាអាទិភាព ............ ២២

៥.២ យុទ្ធសាស្ត្រទី២៖ ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរដែលកបនឹងដំណាំកៅស៊ូ................. ២៣

៥.២.១ គោលបំណង ........................................................................ ២៣

៥.២.២ បញ្ហាប្រឈម ........................................................................ ២៣

៥.២.៣ សកម្មភាពជាអាទិភាព ........................................................... ២៤

៥.៣ យុទ្ធសាស្ត្រទី៣៖ ការជំរុញដំណាំកៅស៊ូគ្រួសារ..................................... ២៤

៥.៣.១ គោលបំណង ........................................................................ ២៤

៥.៣.២ បញ្ហាប្រឈម ........................................................................ ២៥

៥.៣.៣ សកម្មភាពជាអាទិភាព ........................................................... ២៥

៥.៤ យុទ្ធសាស្ត្រទី ៤៖ ការជំរុញចម្ការកៅស៊ូកសិ-ឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍកៅស៊ូគ្រួសារ................................................ ២៥

៥.៤.១ គោលបំណង ........................................................................ ២៥

៥.៤.២ បញ្ហាប្រឈម ........................................................................ ២៦

៥.៤.៣ សកម្មភាពជាអាទិភាព ........................................................... ២៦

៥.៥ យុទ្ធសាស្ត្រទី៥៖ ការជំរុញនិងបង្កើនខ្សែចង្វាក់តម្លៃកៅស៊ូឲ្យបានល្អ............ ២៦

៥.៥.១ គោលបំណង ........................................................................ ២៦

៥.៥.២ បញ្ហាប្រឈម ........................................................................ ២៦

៥.៥.៣ សកម្មភាពជាអាទិភាព ........................................................... ២៧

៥.៦ យុទ្ធសាស្ត្រទី៦៖ ការពង្រឹងតួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូនិងអភិបាលកិច្ច.................................................... ២៨

៣.៦.១ គោលបំណង ........................................................................ ២៨

៣.៦.២ បញ្ហាប្រឈម ........................................................................ ២៩

៣.៦.៣ សកម្មភាពជាអាទិភាព ........................................................... ២៩

**៦. សេចក្តីសន្និដ្ឋាន** ........................................................................ ៣០

**ឧបសម្ព័ន្ធទី ១ ៖** ស្ថិតិផ្ទៃដី ផលិតផល និងផលិតផលកៅស៊ូ ឆ្នាំ១៩២១-១៩៦៧ ............................ ៣១

**ឧបសម្ព័ន្ធទី ២ ៖** ស្ថិតិផ្ទៃដី ផលិតផល និងផលិតផលកៅស៊ូ ឆ្នាំ១៩៨០-២០១០ ............................ ៣២

**ឧបសម្ព័ន្ធទី ៣ ៖** តារាងប៉ាន់ស្មានផ្ទៃដីដាំដុះកៅស៊ូ ឆ្នាំ២០១១-២០២០.......................................... ៣៣

**ឧបសម្ព័ន្ធទី ៤ ៖** ម៉ាទ្រីស ផែនការសកម្មភាពជាអាទិភាព និងថវិកា ក្នុងការអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ឆ្នាំ២០១១-២០២០............................................ ៣៤








# ១. សេចក្តីផ្តើម

## ១.១ សាវតា

ប្រវត្តិដំណាំកៅស៊ូនៅកម្ពុជាបានឆ្លងកាត់ដំណាក់កាលឡើងចុះៗជាបន្តបន្ទាប់ចាប់តាំងពីសម័យអាណានិគមបារាំងរហូតដល់ពេលបច្ចុប្បន្ន។ ក្រោយពីបានទទួលឯករាជ្យ ដោយមានការផ្តួចផ្តើមគំនិត និងការជំរុញយ៉ាងសកម្មរបស់ក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្មបរទេសធំៗ ជាពិសេសក្រុមហ៊ុនកៅស៊ូបារាំង ដំណាំកៅស៊ូបានចាប់ផ្តើមអភិវឌ្ឍតាមគំរូដូចៗគ្នានៅក្នុងតំបន់នៃខេត្តកំពង់ចាមនិងខេត្តក្រចេះ និងបានឈានមកដល់ដំណាក់កាលខ្ពស់បំផុតនៅចុងឆ្នាំ១៩៦៧ ដែលមានផ្ទៃដីកៅស៊ូសរុប ចំនួន៦៤.០៥៤ហិកតា ក្នុងនោះផ្ទៃដីចៀរជ័រមានចំនួន៣៥.៤៦៣ហិកតា ដែលផលិតបានជ័រកៅស៊ូចំនួន៥៣.៧១៦តោន។ ក្រៅពីនោះផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនិងមធ្យម ដែលមានទីតាំងនៅក្បែរចម្ការកៅស៊ូកសិឧស្សាហកម្មធំៗ មានចំនួនជាង ១០.០០០ហិកតា។ *(ឧបសម្ព័ន្ធទី១៖ ស្ថិតិផ្ទៃដី ផលិតផល ទិន្នផល និងនីហរណកម្មកៅស៊ូ ពីឆ្នាំ១៩២១- ១៩៦៧ និងឧបសម្ព័ន្ធទី២៖ ស្ថិតិផ្ទៃដី ផលិតផល ទិន្នផល និងនីហរណកម្មកៅស៊ូ ពីឆ្នាំ១៩៨០- ២០១០)*

ចាប់ឆ្នាំ ១៩៧០មកដល់ឆ្នាំ១៩៧៩ ចម្ការកៅស៊ូមួយផ្នែកធំបានទទួលរងការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសារសង្គ្រាម ជាពិសេសនៅក្រោមរបបគ្រប់គ្រងនៃពួកខ្មែរក្រហម។

ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានប្រមូលផ្តុំចម្ការកៅស៊ូ កសិឧស្សាហកម្មធំៗ ដែលនៅសេសសល់ក្រោយសម័យសង្គ្រាម បានចាប់ផ្តើមស្តារនិងដំណើរការធ្វើអាជីវកម្មឡើងវិញជាបន្តបន្ទាប់តាមរយៈការបង្កើតជាក្រុមហ៊ុនចម្ការកៅស៊ូរដ្ឋ។ នៅឆ្នាំ១៩៩៣ ផ្ទៃដីកៅស៊ូសរុបរបស់ក្រុមហ៊ុនចម្ការកៅស៊ូរដ្ឋទាំង ៦ មានចំនួន៤៣.៥០០ហិកតា និងបានផលិតជ័រកៅស៊ូចំនួនជាង២៥ .០០០តោនក្នុងមួយឆ្នាំ។ ទន្ទឹមនោះរដ្ឋបានកាត់ផ្ទៃដីចម្ការកៅស៊ូមួយចំនួនធំ ដើម្បីប្រគល់ជូនដល់គ្រួសារកសិករដែលបានធ្វើអាជីវកម្មតាំងពីដើមរៀងមក ដោយប្រមូលទឹកជ័រឬជ័រកក មកលក់ឲ្យក្រុមហ៊ុនចម្ការកៅស៊ូរដ្ឋតាមតម្លៃរដ្ឋកំណត់ ។

ក្រោយទសវត្សទី៩០ វិស័យឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាមានការវិវត្តឈានឡើងយ៉ាងឆាប់រហ័សរហូតមកដល់ដំណាក់កាលសេរីភាវូបនីយកម្មនៃវិស័យនេះ។







## ១.២ ស្ថានភាពចម្ការកៅស៊ូបច្ចុប្បន្ន ការវិវត្តនិងសក្តានុពលសម្រាប់រយៈពេលវែង

តាមរយៈគោលនយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាល ចម្ការកៅស៊ូរដ្ឋទាំងអស់ត្រូវបានធ្វើអវិនិយោគដោយបានបង្កើតឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច។ បន្ទាប់មកនៅក្នុងអំឡុងឆ្នាំ២០០៨-២០០៩ ចម្ការកៅស៊ូរដ្ឋទាំងអស់ត្រូវបានធ្វើឯកជនភាវូបនីយកម្ម ដោយបានលក់ទៅឲ្យ ផ្នែកឯកជន។ បច្ចុប្បន្ននេះតាមការកត់សំគាល់នៅកម្ពុជាចម្ការកៅស៊ូទាំងអស់ត្រូវបានបែងចែកជាបីប្រភេទគឺ

១- ចម្ការកៅស៊ូឧស្សាហកម្មទាំង៧ (អតីតចម្ការកៅស៊ូរដ្ឋរួមមានៈ ចម្ការកៅស៊ូចម្ការអណ្តូង បឹងកេត ពាមជាំង ជុប ក្រែក មេមត់ និងស្នួល ) ត្រូវបានផ្ទេរទៅឲ្យក្រុមហ៊ុនឯកជនគ្រប់គ្រងចាប់តាំងពីឆ្នាំ២០០៨-២០០៩ កន្លងមកនេះ។ ក្រៅពីនោះរាជរដ្ឋាភិបាលបានដាក់ជួលចម្ការកៅស៊ូរដ្ឋឡាបានសៀក ខេត្តរតនគីរី ទៅឲ្យក្រុមហ៊ុនបរទេសសម្រាប់រយៈពេល៩០ឆ្នាំ។

២- ចម្ការកៅស៊ូកសិឧស្សាហកម្ម នៅលើដីសម្បទានសេដ្ឋកិច្ចក្នុងទំហំផ្ទៃដីក្រោម១០.០០០ហិកតា ត្រូវបានរាជរដ្ឋាភិបា លសម្រេចផ្តល់ទៅឲ្យវិនិយោគិនក្នុងស្រុកនិងបរទេស ដើម្បីធ្វើការអភិវឌ្ឍដំណាំឧស្សាហកម្ម ដូចជា ម៉ៃសាក់ អាកាស្យា ដូងប្រេង និងកៅស៊ូ ។ល។ គិតរហូតមកដល់ ចុងឆ្នាំ២០១០នេះ ផ្ទៃដីសម្បទានសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលបានផ្តល់រួចហើយសម្រាប់ដំណាំកៅស៊ូមានចំនួន៤៥៧.៧៦៥ហិកតា ដែលក្នុងនោះផ្ទៃដីកាន់កាប់ដោយក្រុមហ៊ុនវិនិយោគបរទេសមានសមាមាត្រ៦២,៥% ខ្ពស់ជាងក្រុមហ៊ុនវិនិយោគក្នុងស្រុក។

៣- ចម្ការកៅស៊ូគ្រួសារតូចតាចនិងមធ្យមដែលមានទំហំខុសៗគ្នា តាមស្ថានភាពនៃការកាន់កាប់ដីចម្ការ។ ចម្ការកៅស៊ូទាំងនេះមានសម្ទុះរីកចម្រើនយ៉ាងឆាប់រហ័សក្នុងមួយទសវត្សកន្លងមកនេះ អាស្រ័យដោយសារការបើកទូលាយគោលនយោបាយសេរីភាវូបនីយកម្មរបស់រាជរដ្ឋាភិបាលលើវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិនិងនិន្នា ការអំណោយផលនៃតម្រូវការរបស់ទីផ្សារពិភពលោកដែលធ្វើឲ្យផលិតផលកៅស៊ូមានតម្លៃខ្ពស់ជាបន្តបន្ទាប់។







នៅក្នុងពេលអនាគត ការធ្វើចំណាត់ថ្នាក់និងការផ្តល់និយមន័យ ចំពោះប្រភេទចម្ការកៅស៊ូទាំងបីខាងលើ អាចនឹងកែសម្រួលឡើងវិញតាមចរិតលក្ខណៈនិងទំហំផ្ទៃដីដែលបានកាន់កាប់ ដូចមានខាងក្រោម៖

- ***ចម្ការកៅស៊ូខ្នាតតូច ឬចម្ការកៅស៊ូគ្រួសារ***ដែលគ្រប់គ្រងដោយអ្នកដាំជាលក្ខណៈគ្រួសារក្នុងទំហំដីក្រោម៥ហិកតា។ ចម្ការកៅស៊ូប្រភេទនេះ បានធ្វើការដាំដុះនៅលើដីចម្ការរបស់ខ្លួនផ្ទាល់ជាមរតក ឬជាដីសម្បទានសង្គមកិច្ចដែលរដ្ឋបានបែងចែកជូនគ្រួសារនីមួយៗ

- ***ចម្ការកៅស៊ូខ្នាតមធ្យម*** ដែលគ្រប់គ្រងដោយអ្នកដាំឯកជន ក្នុងទំហំដីចាប់ពី ៥ហិកតាដល់ ២០០ហិកតា

- ***ចម្ការកៅស៊ូខ្នាតធំ ឬចម្ការកៅស៊ូ កសិឧស្សាហកម្ម*** ដែលគ្រប់គ្រងដោយអ្នកដាំជានីតិបុគ្គល (ជាក្រុមហ៊ុន ជាសមាគម ឬជាសហគមន៍ ) ក្នុងទំហំដីចាប់ពី២០០ហិកតាឡើងទៅ និងប្រើប្រាស់កម្លាំងពលកម្មពីខាងក្រៅ។ ចម្ការកៅស៊ូទាំងនេះរួមមាន ៖ អតីតចម្ការកៅស៊ូរដ្ឋដែលបានធ្វើអវិនិយោគទៅឲ្យក្រុមហ៊ុនឯកជន ចម្ការកៅស៊ូវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងចម្ការកៅស៊ូរដ្ឋដែលបានជួលទៅឲ្យក្រុមហ៊ុនឯកជនរយៈពេលវែង

- ***ចម្ការកៅស៊ូរដ្ឋ***ដែលគ្រប់គ្រងដោយក្រុមហ៊ុនរដ្ឋឬអាជ្ញាធររដ្ឋ និងប្រើប្រាស់កម្លាំងពលកម្មរបស់រដ្ឋ ឬកម្លាំងពលកម្មពីខាងក្រៅ។ ជាទូទៅ រដ្ឋអាចបង្កើតចម្ការកៅស៊ូប្រភេទនេះសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍លើគ្រប់ផ្នែក ដោយគិតចាប់ពីការបង្កាត់ពូជកៅស៊ូដែលមានទិន្នផលខ្ពស់ ដើមធំ (Latex-Timber Clones) ការបង្កើតថ្នាលបណ្តុះកូន ការដាំដុះ ការថែទាំ ការប្រមូលផល ការបង្កក ការកែច្នៃ ការវេចខ្ចប់ និងការស្វែងរកទីផ្សារ។ល។

គិតរហូតមកដល់ចុងឆ្នាំ២០១០នេះ ផ្ទៃដី ដាំដុះកៅស៊ូនៅទូទាំងប្រទេសមានចំនួន១៨១.៤៣៣ហិកតា ដោយបែងចែកទៅតាមប្រភេទចម្ការកៅស៊ូនីមួយៗដូចមាននៅក្នុងតារាងខាងក្រោម៖





## ស្ថិតិផ្ទៃដីកៅស៊ូ ឆ្នាំ២០១០

| ប្រភេទចម្ការកៅស៊ូ | ផ្ទៃដីសម្បទាន (ហ.ត) | ផ្ទៃដីដាំដុះកៅស៊ូ (ហ.ត) | | | | |
|---|---|---|---|---|---|---|
| | | ចៀរជ័រ | ដាំឡើងវិញ | ដាំដុះថ្មី | សរុប | សមាមាត្រ |
| កសិ-ឧស្សាហកម្ម | ៧៤.៥៨៦ | ២០.៩៧១ | ២៣.៦២០ | ២.២៥៣ | ៤៦.៨៤៤ | ២៦% |
| ដីសម្បទានសេដ្ឋកិច្ច | ៤៥៧.៧៦៥ | ០ | ០ | ៥៣.០៧៦ | ៥៣.០៧៦ | ២៩% |
| គ្រួសារខ្នាតតូចនិងមធ្យម | ០ | ១៧.៤៣៥ | ០ | ៦៤.០៧៨ | ៨១.៥១៣ | ៤៥% |
| សរុប | ៥៣២.៣៥១ | ៣៨.៤០៦ | ២៣.៦២០ | ១១៩.៤០៧ | ១៨១.៤៣៣ | ១០០% |

តាមការកត់សំគាល់បានបង្ហាញថាផ្ទៃដីកៅស៊ូមិនទាន់ឲ្យផលមានការកើនឡើងខ្ពស់ អាស្រ័យដោយសារ ៖ (១) ការដាំដុះឡើងវិញរបស់ចម្ការកៅស៊ូឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ)ក្នុងទំហំជាង២៣.៦២០ហិកតា (២)ការដាំដុះរបស់ក្រុមហ៊ុនវិនិយោគនៅលើដីសម្បទានសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន និង(៣) ចាមភាពនៃការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារតូចតាចនិងមធ្យមមានសន្ទុះកើនឡើងយ៉ាងខ្លាំងចាប់តាំងពីដើមទសវត្សនេះ។ នៅក្នុងទសវត្សខាងមុខ ប្រសិនជាស្ថានភាពនេះនៅតែបន្តផ្តល់ភាពអនុគ្រោះ នោះកំណើននៃការដាំដុះនឹងកាន់តែមានសន្ទុះខ្លាំងក្លាថែមទៀត។

ការកត់សំគាល់មួយទៀតនោះគឺ ក្រៅពីចម្ការកៅស៊ូគ្រួសារដែលស្ថិតក្នុងគម្រោងពិសោធន៍របស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD: Agence Francaise de D"veloppement) ចំនួនជាង៣.០០០ហិកតាចម្ការកៅស៊ូតូចតាចនិងមធ្យមរបស់ឯកជនជាច្រើនពាន់ហិកតាផ្សេងទៀតបាននិងកំពុងធ្វើការដាំដុះទៅតាមបច្ចេកទេសនិងថវិកាផ្ទាល់ខ្លួន ដោយពុំមានជំនួយទ្រទ្រង់ណាមួយពីអាជ្ញាធរឡើយ។ ចម្ការកៅស៊ូទាំងនេះមួយចំនួនធំបានប្រើប្រាស់រុក្ខសម្ភារ (Planting Material) សម្រាប់ដាំមិនមានគុណភាព ដែលទៅអនាគតអាចនឹងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើប្រសិទ្ធភាពសេដ្ឋកិច្ច ដោយសារទិន្នផលចុះទាបខុសពីស្តង់ដារធម្មតា។

តាមការអង្កេតផ្ទៃដីដាំដុះកៅស៊ូទូទៅបានបង្ហាញថា ទំហំផ្ទៃដីចម្ការកៅស៊ូដាំដុះដោយខ្លួនឯង ចាប់ពី៥ហិកតាឡើងទៅមានចំនួន ២០%។ ចំណែក ចម្ការកៅស៊ូស្ថិតក្រោម ៥ហិកតាមានត្រឹមតែ ៨០%ប៉ុណ្ណោះនៃផ្ទៃដីដែលបានធ្វើការអង្កេតចំនួន៣.០០០ហិកតាស្មើនឹង៩០០គ្រួសារ *(របាយការណ៍របស់ AFD, ឆ្នាំ 2006)* ។

កន្លងមកនេះ ពាក្យ ថាចម្ការកៅស៊ូគ្រួសារត្រូវបានកំណត់និយមន័យខុស ៗគ្នា នៅតាមបណ្តាប្រទេសផលិតកៅស៊ូក្នុងពិភពលោក ជាពិសេសបណ្តាប្រទេសផលិតកៅស៊ូនៅក្នុងតំបន់អាស៊ី។ ប៉ុន្តែជាទូទៅបណ្តាប្រទេសភាគច្រើនបានកំណត់និយមន័យចំពោះ***ចម្ការកៅស៊ូខ្នាតតូច*** (Rubber Smallholdings) គឺសំដៅការកាន់កាប់ដីត្រឹមក្រោម៥ហិកតា។





យោងតាមទិន្នន័យឆ្នាំ២០១០ បានបង្ហាញថា ទំហំផ្ទៃដីចម្ការកៅស៊ូខ្នាតតូចនិងមធ្យម បានគ្របដណ្តប់ក្នុងសមាមាត្រជាង៤៥%នៃផ្ទៃដីកៅស៊ូសរុប។ ផ្ទៃដីកៅស៊ូស្ថិតក្រោម ដីសម្បទានសេដ្ឋកិច្ច ក៏មានសមាមាត្រមួយកើនឡើងជាបន្តបន្ទាប់នៅក្នុងពេលអនាគត។ ចំណែកឯផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) មានការកើនឡើងដោយតិចតួចប៉ុណ្ណោះ ។

បច្ចុប្បន្ននេះសក្តានុពលនៃដីក្រហមស្ថិតនៅក្នុងតំបន់ប្រពៃណីដែលកបនឹងដំណាំកៅស៊ូ គឺមានកម្រិត។ ក្រៅពីនោះ សក្តានុពលដីប្រភេទផ្សេងទៀតនៅក្នុងតំបន់មិនមែនប្រពៃណីដែលមានលក្ខណៈជាប្រភេទដីខ្សាច់ជ្រៅអាស៊ីត “Red Yellow Podzols” ដីប្រផេះនិងប្រភេទដីផ្សេងទៀតអាចមាននៅសល់ច្រើនសម្រាប់ការដាំដុះកៅស៊ូ អាស្រ័យលើការសិក្សាស្រាវជ្រាវបន្ថែមអំពីលក្ខណៈនិងស្ថានភាពដីនៅកម្ពុជា។ តំបន់ទាំងនេះអាចនឹងអភិវឌ្ឍកៅស៊ូបានលុះត្រាតែមានការកំណត់ព្រំប្រទល់ច្បាស់លាស់អំពីតំបន់ដែនព្រៃឈើដែលត្រូវការពារនិងតំបន់ដីដែលត្រូវធ្វើការអភិវឌ្ឍកសិកម្ម ។

## ១.៣ ការកែច្នៃជ័រកៅស៊ូ

រោងចក្រកែច្នៃជ័រកៅស៊ូនៅតាមចម្ការកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) បានដំណើការកែច្នៃជ័រកៅស៊ូដែលប្រមូលបានពីក្នុងចម្ការកៅស៊ូរបស់ខ្លួន និងបានផលិតកៅស៊ូមានគុណភាពល្អតាមលក្ខណៈបច្ចេកទេស។ គុណភាពជ័រកៅស៊ូដែលផលិតចេញពីរោងចក្ររួមមាន៖ ប្រភេទ CSRL CSR5 CSR10 និងCSR20។ បរិមាណកៅស៊ូដែលផលិតចេញពីរោងចក្ររបស់ចម្ការកៅស៊ូនីមួយៗភាគច្រើនលើសលុប គឺជាប្រភេទ CSRL និងCSR5 ដែលមានតម្លៃខ្ពស់នៅលើទីផ្សារអន្តរជាតិ។ ក៏ប៉ុន្តែ តម្រូវការនៃទីផ្សារពិភពលោកសម្រាប់កៅស៊ូប្រភេទនេះគឺមានចំនួនតិចតួចណាស់។ ផ្ទុយទៅវិញ នៅបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្នុងពិភពលោក គេបានផលិតកៅស៊ូប្រភេទ CSR10 និង CSR20 ក្នុងបរិមាណដ៏ច្រើន អាស្រ័យដោយសារមានតម្រូវការ ច្រើននៃទីផ្សារសម្រាប់ជ័រកៅស៊ូប្រភេទនេះ ជាពិសេស សម្រាប់រោងចក្រនិងកម្មន្តសាលធំៗដែលផលិតសំបកកង់រថយន្ត។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រោងចក្រកែច្នៃជ័រកៅស៊ូទាំងអស់ (ទាំងធំ ទាំងតូច) បានប្រមូលទិញជ័រកៅស៊ូមួយផ្នែកពីចម្ការកៅស៊ូគ្រួសារ (តាមរយៈឈ្មួញកណ្តាលឬម្ចាស់ចម្ការកៅស៊ូផ្ទាល់) ឬជួនកាលអាចធ្វើសេវាស៊ីឈ្នួលកែច្នៃឲ្យអ្នកប្រមូលទិញឬម្ចាស់ចម្ការកៅស៊ូខ្លះៗដែរ។ ជ័រកៅស៊ូដែលប្រមូលទិញឬស៊ីឈ្នួលកែច្នៃនេះភាគច្រើនគឺជាជ័រចានឬជ័រកក ដែលមានភាពងាយស្រួលក្នុងការដឹកជញ្ជូន ហើយគុណភាពកៅស៊ូដែលផលិតចេញពីរោងចក្រគឺជាប្រភេទCSR10 និង CSR20។





បច្ចុប្បន្ននេះ សមត្ថភាពកែច្នៃជ័រកៅស៊ូនៅសល់ច្រើន បើប្រៀបជាមួយបរិមាណជ័រកៅស៊ូដែលត្រូវកែច្នៃ។ ម្យ៉ាងទៀត ចំណាយសេវាកែច្នៃ នៅមានកម្រិតខ្ពស់ (៩៧ដុល្លារក្នុងមួយតោនគិតជាមធ្យម គឺខ្ពស់ជាង៣០%នៃសេវាកែច្នៃនៅវៀតណាម)។ កត្តាដែលធ្វើឲ្យសេវាកែច្នៃជ័រកៅស៊ូនៅកម្ពុជាឡើងខ្ពស់រួមមាន ៖ សមត្ថភាពលើសលុបនៃរោងចក្រ តម្លៃថាមពលខ្ពស់ និងចំណាយផ្សេងៗក៏ខ្ពស់ដែរ។ ក៏ប៉ុន្តែ ប្រសិទ្ធភាពទូទៅនៃការលក់ដូរនិងការកែច្នៃគឺមានដំណើរការល្អនិងកំពុងកែលំអបន្ថែមនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ម្យ៉ាងទៀត ស្ថានភាពនៃតម្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិចេះតែឡើងខ្ពស់ជាបន្តបន្ទាប់ ដោយ  សារតម្រូវការកើនឡើងខ្ពស់ហើយការផ្គត់ផ្គង់កៅស៊ូរួមនៅក្នុងពិភពលោកបានធ្លាក់ចុះ ដោយសារឥទ្ធិពលនៃ    បម្រែបម្រួលអាកាសធាតុដែលបង្កឲ្យមានភាពរាំងស្ងួត ភ្លៀងធ្លាក់ខ្លាំងមិនប្រក្រតី ទឹកជំនន់ និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ នៅក្នុងបណ្តាប្រទេសជាច្រើន ជាពិសេសបណ្តាប្រទេសផលិតកៅស៊ូធំៗនៅតំបន់អាស៊ីដូចជា ប្រទេសថៃ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ឥណ្ឌាជាដើម ដែលធ្វើឲ្យប៉ះពាល់ដល់ការប្រមូលផលជ័រនិងការដឹកជញ្ជូន។

## ១.៤ ការធ្វើពាណិជ្ជកម្ម

ជារៀងរាល់ឆ្នាំ បរិមាណផលិតផលកៅស៊ូកម្ពុជាត្រូវបានធ្វើការនាំចេញទៅបរទេសស្ទើរតែទាំងអស់។ ទីផ្សារសំខាន់ដែលស្រូបយកផលិតផលកៅស៊ូកម្ពុជា គឺទីផ្សារចិន។ តាំងពីមុនរហូតមកដល់បច្ចុប្បន្ន ការនាំចេញកៅស៊ូទៅកាន់ប្រទេសចិន  គឺឆ្លងកាត់តាមប្រទេសវៀតណាម។ ក្រៅពីនោះ កៅស៊ូកម្ពុជាត្រូវបាននាំចេញក្នុងបរិមាណតិចតួចទៅកាន់ទីផ្សារអឺរ៉ុបនិងអាស៊ីអគ្នេយ៍ដូចជា  សឹង្ហបុរី  ម៉ាឡេស៊ី។ល។ តម្លៃជ័រកៅស៊ូដែលកម្ពុជាបាននាំចេញគឺទាបជាងតម្លៃទីផ្សារអន្តរជាតិក្នុងកម្រិតពី១០ ទៅ១៥ %។ ស្ថានភាពនេះបានបង្ហាញឲ្យឃើញ ថា៖ (១)អំពីភាពតូចចង្អៀតនៃទីផ្សារកៅស៊ូប្រភេទនេះ  (២)អំពីភាពទន់ខ្សោយផ្នែកហិរញ្ញវត្ថុរបស់អ្នកនាំចេញដែលត្រូវការសាច់ប្រាក់ភ្លាមៗបន្ទាប់ពីការប្រគល់ទំនិញរួច និង (៣)អំពីកង្វះខាតបទពិសោធន៍នៅក្នុងការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។

ម្យ៉ាងទៀត ការកង្វះខាតវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូជាលក្ខណៈអន្តរជាតិ ក៏ជាមូលហេតុបន្ទាប់បន្សំមួយដែរ ដែលធ្វើឲ្យតម្លៃកៅស៊ូអាចចុះទាបមួយកម្រិត ជាពិសេសការ  ធ្វើពាណិជ្ជកម្មជាមួយអ្នកប្រើប្រាស់កៅស៊ូផ្ទាល់ (End-Users)។ ប៉ុន្តែករណីនេះមិនមែនជាកត្តាកំណត់ទូទៅសម្រាប់ទីផ្សារកៅស៊ូឡើយ។





## ១.៥ ក្របខណ្ឌច្បាប់

ច្បាប់ភូមិបាល ដែលត្រូវបានដាក់ឲ្យអនុវត្តចាប់តាំងពីឆ្នាំ២០០១មក បានហាមឃាត់រាល់ការដាំដុះនៅក្នុងតំបន់ព្រៃឈើ (ដោយចាត់ទុកថាជាចំណែកមួយនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ) និងអាចអនុញ្ញាតឲ្យធ្វើការដាំដុះនិងចូលកាន់កាប់កម្មសិទ្ធិដីធ្លីបាននៅក្នុងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ(ក្រៅពីតំបន់ព្រៃឈើ)។

ក៏ប៉ុន្តែ តំបន់ព្រៃឈើដែលបានកំណត់ នៅក្នុងច្បាប់ឆ្នាំ២០០២កំពុងទទួលរងការកាប់ទន្ទ្រាននិងដុតរានយ៉ាងខ្លាំង។ តំបន់ព្រៃឈើមួយចំនួនធំគ្មានការគ្រប់គ្រងច្បាស់លាស់ដែលអាចបង្កឲ្យមានទំនាស់ក្នុងការកាប់ឈើដោយខុសច្បាប់និងការរំលោភបំពានចាប់យកដីសម្រាប់ជាផលប្រយោជន៍របស់បុគ្គលនិងបក្ខពួក។ ផ្ទៃដីមួយផ្នែកធំបានប្រែក្លាយទៅជាចម្ការកៅស៊ូ ជាពិសេសចម្ការកៅស៊ូគ្រួសារឯកជនខ្នាតតូច មធ្យម និងចម្ការកៅស៊ូខ្នាតធំខ្លះនៅក្នុងតំបន់ព្រៃឈើហើយដែលមិនមានកម្មសិទ្ធិត្រឹមត្រូវនិងស្របច្បាប់ឡើយ។

ម្យ៉ាងទៀត រហូតមកដល់ពេលនេះ តំបន់ព្រៃឈើភាគច្រើននៅមិនទាន់បានកំណត់ព្រំប្រទល់ច្បាស់លាស់ គួបផ្សំនឹងការអនុវត្តន៍ច្បាប់នៅមានកម្រិត និងតម្រូវការដីធ្លីសម្រាប់ប្រើប្រាស់និងធ្វើអាជីវកម្មកើនឡើងខ្ពស់ អាចជាមូលហេតុជំរុញឲ្យមានការរំលោភទន្ទ្រានចាប់យកដីព្រៃឈើ ការធ្វើចម្ការពនេចរគ្មាននិរន្តរភាព។

១. ដើម្បីដោះស្រាយបញ្ហាប្រឈមនិងទំនាស់ខាងលើ រាជរដ្ឋាភិបាលបានប្តេជ្ញានិងដាក់ចេញនូវ "កម្មវិធីព្រៃឈើជាតិឆ្នាំ២០១០ -២០២៩ " ក្នុងគោលបំណងរួមគឺអភិរក្សនិងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ក្រៅពីនេះ កម្មវិធីព្រៃឈើជាតិក៏បានកំណត់ច្បាស់អំពីគោលបំណងជាយុទ្ធសាស្ត្រធំៗទាំង៩គឺ ៖ (១)បង្កើនការទទួលផលប្រយោជន៍ពីព្រៃឈើ (២)បន្សាំនិងកាត់បន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ (៣)រៀបចំផែនការប្រើប្រាស់ដីធ្លី (៤)ពង្រឹងអភិបាលកិច្ចនិងការអនុវត្តច្បាប់គ្រប់កម្រិត (៥)ពង្រីកប្រព័ន្ធគ្រប់គ្រងទំនាស់ទាំងក្នុងនិងក្រៅប្រព័ន្ធតុលាការ (៦)អភិវឌ្ឍសមត្ថភាពមនុស្សនិងស្ថាប័ន (៧)ធានាការអភិរក្សធនធានព្រៃឈើនិងការការពារបរិស្ថាន (៨)ជ្រើសរើសរបបគ្រប់គ្រងព្រៃឈើ និង (៩)ហិរញ្ញប្បទានជានិរន្តន៍សម្រាប់វិស័យព្រៃឈើ។

២. ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃកម្មវិធីព្រៃឈើជាតិ រាជរដ្ឋាភិបាលបានកំណត់នូវនិយមន័យព្រៃឈើដូចតទៅ៖ ព្រៃឈើគឺជាឯកតានៃប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិឬសិប្បនិមិត្ត ក្រោមទម្រង់ជាដីសើមឬដីស្ងួតដែលគ្របដណ្តប់ដោយរុក្ខជាតិដុះដោយធម្មជាតិឬដាំមានកំពស់ចាប់ពី៥ម៉ែត្រឡើងលើ ផ្ទៃដីលើសពី០,៥ហិកតានិងមានកម្រិតគ្របដណ្តប់របស់កន្សោមស្លឹកលើសពី១០ភាគរយ។ ចម្ការឈើដាំដូចជា កៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងប្រភេទរុក្ខជាតិផ្តល់ឈើដទៃទៀតដែលមានលក្ខណៈដូចរៀបរាប់ខាងលើក៏ត្រូវបានចាត់ចូលជាព្រៃដែរ ។





៣. ដំណើរការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងចុះបញ្ជីសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ គឺជាដំណើរការដើម្បីធានានូវកម្មសិទ្ធិនិងសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន។

ក្នុងន័យនេះ ទៅអនាគតចម្ការកៅស៊ូគ្រួសារខ្នាតតូចអាចនឹងត្រូវចុះបញ្ជីសម្រាប់ផ្តល់កម្មសិទ្ធិតទៅ។ ម្យ៉ាងទៀត ផ្ទៃដីដែលត្រូវកាត់ចេញពីផែនទីតម្រុបព្រៃឈើ គឺជាផ្ទៃដីដែលប្រជាពលរដ្ឋកំពុងកាន់កាប់ជាក់ស្តែងមានលក្ខណៈសមហេតុសមផលនិងមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវចាត់ទុកថាជាដីសម្បទានសង្គមកិច្ចរបស់រដ្ឋសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋ។

## ១.៦ ក្របខណ្ឌស្ថាប័ន

អគ្គនាយកដ្ឋានកៅស៊ូគឺជាអាជ្ញាធររាជរដ្ឋាភិបាល ដែលចំណុះក្រោម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការគ្រប់គ្រងឧស្សាហកម្មកៅស៊ូធម្មជាតិចាប់ពីខ្សែលំហូរខាងលើ (upstream) ដល់ខ្សែលំហូរខាងក្រោម (downstream)។ ជាមួយគ្នានោះ បណ្តា ក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្សេងទៀតត្រូវមានភារកិច្ចតាមមុខជំនាញរបស់ខ្លួនរួមមាន៖

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទទួលបន្ទុកអនុវត្តគោលនយោបាយដីធ្លី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកអនុវត្តគោលនយោបាយពន្ធដារនិងការប្រមូលពន្ធនាំ - ចេញកៅស៊ូ
- ក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកអនុវត្តបទដ្ឋាននិងការធ្វើពាណិជ្ជកម្មផលិតផលកៅស៊ូ
- ក្រសួងបរិស្ថាន ទទួលបន្ទុកអនុវត្តការត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលបន្ទុកអនុវត្តការត្រួតពិនិត្យសកម្មភាពរោងចក្រ ផលិតទំនិញចេញពីជ័រកៅស៊ូ (Rubber-based Products) ។

ក៏ប៉ុន្តែ ក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍដំណាំកៅស៊ូទូទៅ អគ្គនាយកដ្ឋានកៅស៊ូ គឺជាអង្គភាពសម្របសម្រួលមួយក្នុងការអនុវត្តន៍ការងារប្រកបដោយសុខដុមនីយកម្ម ជាមួយបណ្តាក្រសួងឬស្ថាប័នដែលមានការពាក់ព័ន្ធទាំងនោះ ព្រមទាំងធ្វើសហប្រតិបត្តិការជាមួយអង្គការកៅស៊ូអន្តរជាតិនានារួមមាន សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍកៅស៊ូអន្តរជាតិ សមាគមកៅស៊ូអន្តរជាតិ ក្រុមសិក្សាកៅស៊ូអន្តរជាតិ នៅក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូ។





យោងតាមអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានសម្រេចកែសម្រួលរចនាសម្ព័ន្ធអគ្គនាយកដ្ឋានកៅស៊ូក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានជំនាញចំនួន៥ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូមួយស្ថិតក្រោមឱវាទ ឲ្យទទួលខុសត្រូវគ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍវិស័យកៅស៊ូនៅទូទាំងប្រទេស ។

ក៏ប៉ុន្តែ អគ្គនាយកដ្ឋានកៅស៊ូ មិនទាន់មានលទ្ធភាពអនុវត្តការងារឲ្យបានសមស្របតាមគោលបំណង និងបេសកកម្មរបស់ខ្លួនឡើយ។ ចំណុចខ្វះខាតបីជាសំខាន់ដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការជាច្រើនរបស់អគ្គនាយកដ្ឋាន គឺធនធានមនុស្ស មធ្យោបាយធ្វើការងារ និងធនធានហិរញ្ញវត្ថុ។

## ១.៧ លក្ខណៈសម្បត្តិ (advantage) នៃការអភិវឌ្ឍដំណាំកៅស៊ូនៅកម្ពុជា

បើប្រៀបធៀបជាមួយបណ្តាប្រទេសផលិតកៅស៊ូសំខាន់ៗនៅក្នុងតំបន់អាស៊ី ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាមានលក្ខណៈសម្បត្តិល្អជាច្រើនដូចជា៖

- ចំណាយវិនិយោគក្នុងការដាំដុះសមស្រប (ក្នុងតម្លៃ ១.៥០០ដុល្លារសហរដ្ឋក្នុងមួយហិកតាសម្រាប់ចម្ការកៅស៊ូគ្រួសារនិង ៣.៥០០ដុល្លាសហរដ្ឋក្នុងមួយហិកតាសម្រាប់ចម្ការកៅស៊ូកសិឧស្សាហកម្ម)
- ឈ្នួលពលកម្មទាប
- ទិន្នផលជ័រកៅស៊ូខ្ពស់ ប្រសិនជាមានការគ្រប់គ្រងនិងថែទាំដោយត្រឹមត្រូវ
- ទទួលរងផលប៉ះពាល់តិចតួចពីជម្ងឺនិងសត្វចង្រៃ
- ទទួលបានប្រាក់ចំណូលខ្ពស់ ជាពិសេសចំពោះកៅស៊ូគ្រួសារដែលជាកម្លាំងចលករមួយនៃការអភិវឌ្ឍនៅជនបទនិងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ។

ដោយឡែក លើផ្នែកសេដ្ឋកិច្ចនិងសង្គម ចម្ការកៅស៊ូគ្រួសារបានបង្ហាញឲ្យឃើញអំពីផលប្រយោជន៍ខ្ពស់ជាងចម្ការកៅស៊ូកសិឧស្សាហកម្មដូចជា៖ ប្រាក់ចំណូលខ្ពស់និ ងថេរ កម្លាំងពលកម្ម គ្រួសារមានលទ្ធភាពអាចទប់ទល់បាននៅពេលមានការប្រែប្រួលជាយថាហេតុនៃទីផ្សារ និងជាប្រភពទុនថិតថេរសម្រាប់កសិករតូចតាច។ លទ្ធផលទាំងនេះបានបង្ហាញថា ផលប្រយោជន៍សំខាន់នៃការអភិវឌ្ឍដំណាំកៅស៊ូនៅក្នុងពិភពលោកនាពេលថ្មីៗនេះ គឺផ្តើមចេញមកពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារ។ ជាក់ស្តែង ផ្ទៃដីចម្ការកៅស៊ូគ្រួសារតូចតាចនៅប្រទេសឥណ្ឌូណេស៊ី ថៃ ម៉ាឡេស៊ី ឥណ្ឌាបានគ្របដណ្តប់ពី៨០ ទៅ៨៧ ភាគរយនៃផ្ទៃដីកៅស៊ូសរុបរបស់ប្រទេស។





## ១.៨ ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងហានិភ័យ

| ភាពខ្លាំង (Strengths) | ភាពខ្សោយ (Weaknesses) |
|---|---|
| ថាមភាពខ្លាំងនៃចម្ការកៅស៊ូដាំដុះដោយខ្លួនឯង | ខ្វះជំនឿលើគុណភាពរុក្ខសម្ភារ |
| មានកម្រៃខ្ពស់ចំពោះតម្លៃកៅស៊ូបច្ចុប្បន្ន និងភាពប្រកួតប្រជែងខ្លាំង | ច្បាប់និងលិខិតគតិយុត្តិ ពាក់ព័ន្ធនឹងដីធ្លីមិនអាចអនុវត្តបាន បង្កឲ្យមានភាពអាណាធិបតេយ្យក្នុងការទន្ទ្រាន កាន់កាប់ និងជួញដូរដីធ្លី |
| សក្តានុពលនៃដីមិនទាន់ប្រើប្រាស់ ជាពិសេសនៅតំបន់ថ្មី | ខ្វះគោលនយោបាយវិសាលគមជាតិ ក្នុងការជំរុញដំណាំកៅស៊ូគ្រួសារ |
| ភាពម្ចាស់ការល្អនៃដំណាំកៅស៊ូនៅក្នុងតំបន់ប្រពៃណី | ថវិកា មធ្យោបាយ និងធនធានមនុស្សរបស់អគ្គនាយកដ្ឋានកៅស៊ូនៅមានកម្រិត |
| ផលប្រយោជន៍ប្រកបដោយប្រៀបនៃវិស័យកៅស៊ូនៅកម្ពុជា | ខ្វះសកម្មភាពសម្របសម្រួល រវាងអគ្គនាយកដ្ឋានកៅស៊ូ ចម្ការកៅស៊ូកសិឧស្សាហកម្ម និងចម្ការកៅស៊ូគ្រួសារ |
| **កាលានុវត្តភាព (Opportunities)** | **ហានិភ័យ (Risk)** |
| ផលប្រយោជន៍ម៉ាក្រូសេដ្ឋកិច្ចសម្រាប់ប្រទេសជាតិ | ផលវិបាកនៃចម្ការកៅស៊ូគ្រួសារ ស្ថិតក្នុងតំបន់មិនមែនប្រពៃណី ដូចជាគុណភាពរុក្ខសម្ភារមិនល្អ និងមិនមានការណែនាំបច្ចេកទេស |
| ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារអាចជំរុញ និងកាត់បន្ថយភាពក្រីក្រនៅជនបទ | ការចូលរួមតិចតួចរបស់កសិករតូចតាចឬកសិករក្រីក្រនៅក្នុងថាមភាពនៃការដាំដុះកៅស៊ូ |
| ការអភិវឌ្ឍដំណាំកៅស៊ូ គឺជាចម្លើយដ៏ត្រឹមត្រូវចំពោះបញ្ហាតំបន់ព្រៃឈើដែលរេចរឹលខ្លាំង | ខ្វះកិច្ចសហប្រតិបត្តិការរវាងស្ថាប័នអនុវត្តនិងអាជ្ញាធរមូលដ្ឋាន ក្នុងការទទួលពត៌មាននិងស្ថិតិកៅស៊ូ |



## ១.៩ បញ្ហាប្រឈម

ដំណាំកៅស៊ូបានប្រឈមជាមួយបញ្ហាជាយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនដូចតទៅ៖

- រុក្ខសម្ភារនៃចម្ការកៅស៊ូដាំដុះដោយខ្លួនឯងដែលមិនមានគុណភាពល្អ បានធ្វើឲ្យទិន្នផលជ័រកៅស៊ូចុះទាបជាងស្តង់ដារធម្មតា។ ប្រសិនជាមិនមានការកែលំអស្ថានភាពរុក្ខសម្ភារនេះទេ ទៅអនាគតអ្នកដាំនឹងត្រូវទទួលរងការខាតបង់ផលិតផលជ័រកៅស៊ូយ៉ាងច្រើន។ នៅក្នុងរយៈពេល១៥ឆ្នាំទៅមុខ ចាប់តាំងពីឆ្នាំ២០១១តទៅផលិតផលកៅស៊ូដែលបានដាំដុះថ្មី ដោយគិតតាមចង្វាក់ដាំដុះ ៥.០០០ហិកតាក្នុងមួយឆ្នាំ របស់កសិករតូចតាច (ដោយមិនគិតការដាំដុះរបស់ចម្ការកៅស៊ូកសិឧស្សាហកម្ម) នឹងបង្ហាញឲ្យឃើញនូវការបាត់បង់ក្នុងបរិមាណចំនួន១៦៥.០០០តោន។ ដូច្នេះ ការបាត់ចំណូលនេះបើគិតជាតម្លៃវិញ គឺមានរហូតដល់៥៧៧,៥លានដុល្លារសហរដ្ឋសម្រាប់រយៈពេល១០ឆ្នាំក្រោយ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២៦ (លើមូលដ្ឋានថ្លៃ៣៥០០ដុល្លារក្នុងមួយតោន) ដែលគិតជាមធ្យមគឺមានចំនួន៥៧,៧៥លានដុល្លារក្នុងមួយឆ្នាំ។

**ការបាត់បង់ចំណេញបណ្តាលមកពីការប្រើប្រាស់រុក្ខសម្ភារមិនល្អ**




- ផលប៉ះពាល់នៃដីធ្លី ថវិកា និងបច្ចេកទេស បានធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍកៅស៊ូគ្រួសារនិងធ្វើឲ្យមានហានិភ័យនៅក្នុងការកំណត់ព្រំដែនថាមភាពនៃការដាំដុះកៅស៊ូបច្ចុប្បន្ន ។



## ១.១០ សកម្មភាពជាអាទិភាព

ផ្អែកលើមូលដ្ឋាននៃការវិភាគនេះ អគ្គនាយកដ្ឋានកៅស៊ូបានដាក់ចេញនូវសកម្មភាពជាអាទិភាពចំនួន ៥ តាមលំដាប់ដូចខាងក្រោម៖

### ក- ការត្រួតពិនិត្យនិងការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា នៃអគ្គនាយកដ្ឋានកៅស៊ូ ត្រូវចុះត្រួតពិនិត្យច្បារពូជកៅស៊ូទាំងអស់ ដែលបានបង្កើតរួចហើយនិងដែលនឹងត្រូវបង្កើតថ្មីនៅទូទាំងប្រទេស ដើម្បីធ្វើការណែនាំ សម្របសម្រួល និង ផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពចំពោះច្បារពូជណា ដែលបានរៀបចំល្អត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយអនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៥៤៤ ប្រក .កសក. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពីការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូនិងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ។

### ខ- ច្បាប់ស្តីពីកៅស៊ូ

ច្បាប់នេះមានគោលបំណងធានាការគ្រប់គ្រងនិងការអភិវឌ្ឍដំណាំកៅស៊ូនៅទូទាំងប្រទេស សម្រាប់ បម្រើផលប្រយោជន៍សេដ្ឋកិច្ចជាតិ សង្គម បរិស្ថាន និង ជាពិសេសសម្រាប់អ្នកដាំកៅស៊ូជានីតិបុគ្គលឬជារូបវន្ត បុគ្គល។

រហូតមកដល់បច្ចុប្បន្ននេះ នៅបណ្តាប្រទេសផលិតកៅស៊ូមួយចំនួនធំមិនទាន់មានច្បាប់ស្តីពីកៅស៊ូនៅ ឡើយទេ។ ម្យ៉ាងទៀត បណ្តាប្រទេសដែលបានបង្កើតច្បាប់កៅស៊ូរួចហើយក៏ដោយ ក៏មិនបានលើកឡើងឲ្យបាន ស៊ីជម្រៅទៅលើវិស័យកៅស៊ូទាំងស្រុងដែរ។ ឧទាហរណ៍ ច្បាប់កៅស៊ូនៅប្រទេសម៉ាឡេស៊ីនិងឥណ្ឌា ដែលមាន ឈ្មោះថា (Rubber Act) គឺគ្រាន់តែរៀបរាប់អំពីការបង្កើតក្រុមប្រឹក្សាកៅស៊ូ មុខងារ ប្រាក់បៀវត្ស មូលនិធិ និង អំណាចរបស់ក្រុមប្រឹក្សាប៉ុណ្ណោះ។ ចំណែកនៅប្រទេសស្រីលង្កា ច្បាប់ស្តីពីការត្រួតពិនិត្យកៅស៊ូ (Rubber Control Act) បានលើកឡើងអំពីការចុះបញ្ជីចម្ការកៅស៊ូទាំងអស់ (ទាំងតូច ទាំងធំ ) នីតិវិធីនៃការចុះបញ្ជី ការផាកពិន័យ ការត្រួតពិនិត្យកៅស៊ូ និងការអនុញ្ញាតឲ្យធ្វើការដាំដុះថ្មីនិងដាំដុះឡើងវិញ ការផ្តល់អាជ្ញាប័ណ្ណ ក្នុងការកាន់កាប់ ការទិញ ការលក់ ការស្តុក ការកែច្នៃ ការនាំចេញនាំចូល ការផ្តល់ព័ត៌មាន និងរបាយការណ៍ ...។ល។ និយាយជារួម ច្បាប់កៅស៊ូនៅក្នុងបណ្តាប្រទេសទាំងនោះ គឺច្រើនរៀបរាប់និងអនុវត្តទៅតាមស្ថានភាព ជាក់ស្តែងនៃសេដ្ឋកិច្ច សង្គម ទម្លាប់ និងប្រពៃណីរបស់ប្រទេសរបស់ខ្លួន ។





ចំណែកនៅកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូបាននិងកំពុងចងក្រងច្បាប់ស្តីពីកៅស៊ូដោយខ្លួនឯង ដោយមិនបានជ្រើសរើសយកច្បាប់ប្រទេសណាមួយធ្វើជាគំរូបានឡើយ។ អគ្គនាយកដ្ឋានខ្វះខាតមធ្យោបាយជាច្រើន ដូចជា ថវិកា ធនធានមនុស្ស ឯកសារយោង និងមិនមានការជួយទ្រទ្រង់ឬឧបត្ថម្ភពីអង្គការឬដៃគូអភិវឌ្ឍន៍ណាមួយ ដើម្បីមកជួយរៀបចំតាក់តែងសេចក្តីព្រាងច្បាប់នេះ ឲ្យមានលក្ខណៈសមស្របតាមស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសនិងផ្សារភ្ជាប់ជាមួយអន្តរជាតិឡើយ ។

## គ- ផែនការសកម្មភាពនិងការរៀបចំថវិការបស់អគ្គនាយកដ្ឋានកៅស៊ូ

ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាពសមស្របតាមចក្ខុវិស័យ បេសកកម្ម គោលបំណងនិងគោលដៅអភិវឌ្ឍកៅស៊ូធម្មជាតិតាមតំណាក់កាលនីមួយៗ អគ្គនាយកដ្ឋានកៅស៊ូត្រូវរៀបចំផែនការសកម្មភាពនិងថវិកាដែលត្រូវបានពិនិត្យ និងអនុម័តដោយរាជរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ឃ- ការអនុវត្តផែនការសកម្មភាព និងការគិតគូរដល់គោលដៅយុទ្ធសាស្ត្រ

ក្នុងន័យនេះ ការរៀបចំរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានកៅស៊ូ ចាំបាច់ត្រូវដំណើរការចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ដោយត្រូវ៖

១- រៀបចំបង្កើតការិយាល័យដំណាំកៅស៊ូនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

២- រៀបចំបង្កើតស្នាក់ការនិងចាត់តាំងមន្ត្រីប្រចាំការនៅតាមមាត់ច្រកនាំចេញនាំចូលកៅស៊ូ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីត្រួតពិនិត្យសកម្មភាពនៃការនាំចេញនាំចូលជ័រកៅស៊ូ រុក្ខសម្ភារកៅស៊ូ គ្រឿងម៉ាស៊ីន ទព្វសម្ភារ គ្រឿងបន្លាស់ ដែលពាក់ព័ន្ធដល់វិស័យកៅស៊ូ។

៣- កៀរគររកជំនួយឬឥណទាន សម្រាប់ការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារតូចតាចនៅលើដីចម្ការរបស់ខ្លួន ឬនៅលើដីសម្បទានសង្គមកិច្ចរបស់រដ្ឋ។

៤- ជំរុញការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារដែលមានទីតាំងស្ថិតនៅក្បែរចម្ការកៅស៊ូកសិឧស្សាហកម្ម។

៥- សម្របសម្រួលការធ្វើពាណិជ្ជកម្មអន្តរជាតិ ការចូលមកកាន់ទីផ្សារកៅស៊ូកម្ពុជារបស់អតិថិជនអន្តរ-ជាតិ ការពង្រីកឧស្សាហកម្មកែច្នៃកៅស៊ូ ការប្រមូលទិញជ័រកៅស៊ូដោយភាពប្រកួតប្រជែងនិងស្មោះត្រង់។





## ខ- ការសិក្សាអំពីហិរញ្ញប្បទាននិងសកម្មភាពជួយទ្រទ្រង់អគ្គនាយកដ្ឋានកៅស៊ូ

សិក្សាអំពីលទ្ធភាពអាចធ្វើបានក្នុងការកែសម្រួលភារកិច្ចរបស់អគ្គនាយកដ្ឋានកៅស៊ូ ដើម្បីឲ្យក្លាយទៅជាអង្គភាពសម្របសម្រួលមួយដែលមានរចនាសម្ព័ន្ធចំណុះរដ្ឋមន្ត្រីមានសិទ្ធិអំណាច និងស្វ័យភាពហិរញ្ញវត្ថុគប់គ្រាន់។









## ២. ចក្ខុវិស័យ

ចក្ខុវិស័យរយៈពេលវែងសម្រាប់វិស័យកៅស៊ូ គឺជំរុញឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាប្រកបដោយថាមភាពខ្លាំង និងមានភាពប្រកួតប្រជែង ដោយផ្តល់អាទិភាពសម្រាប់ដំណាំកៅស៊ូគ្រួសារ សំដៅជួយបង្កើនប្រាក់ចំណូលទៀងទាត់ដល់អ្នកដាំកៅស៊ូ ការបង្កើតអាជីពនៅជនបទ ចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តរភាព។

## ៣. បេសកកម្ម

អភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តរភាពនិងវឌ្ឍនភាព។

## ៤. គោលបំណងនិងគោលដៅ

យុទ្ធសាស្ត្រវិស័យកៅស៊ូដែលបានចែងនៅក្នុងយុទ្ធសាស្ត្រកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល បានកំណត់អំពីគោលដៅជាយុទ្ធសាស្ត្រមួយចំនួនដែលនៅក្នុងនោះ ដំណាំកៅស៊ូបានបង្កើនប្រាក់ចំណូលនិងអាជីពនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

គោលដៅនៃការអភិវឌ្ឍវិស័យនេះ គឺសមស្របតាមចក្ខុវិស័យរយៈពេលវែងនិងគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរួមមាន៖ ការលើកកម្ពស់សក្តានុពលនៃដំណាំកៅស៊ូរបស់ជាតិ ឲ្យទទួលបានទាំងបរិមាណនិងគុណភាព តាមរយៈការដាំដុះកៅស៊ូប្រកបដោយទិន្នផលខ្ពស់ ដោយផ្តល់អាទិភាពដល់ចម្ការកៅស៊ូគ្រួសារ និងជំរុញខ្សែចង្វាក់តម្លៃឲ្យបានខ្ពស់ជាអតិបរិមា។ តាមការនិទស្សន៍ រហូតដល់ឆ្នាំ២០២០ ផ្ទៃដីកៅស៊ូនៅទូទាំងប្រទេសនឹងមានចំនួនជាង៣០០.០០០ហិកតានិងមានបរិមាណផលិតផលចំនួនជាង២៥០.០០០តោនក្នុងមួយឆ្នាំ *(ឧបសម្ព័ន្ធទី ៣)*។

ជាទូទៅការលើកកម្ពស់សក្តានុពលកៅស៊ូជាតិត្រូវអនុវត្តតាមរយៈការបន្តថាមភាពនៃចម្ការកៅស៊ូគ្រួសារដែលត្រូវតែជួយទ្រទ្រង់ និងតាមរយៈការអភិវឌ្ឍចម្ការកៅស៊ូឧស្សាហកម្មថ្មីៗ នៅក្នុងតំបន់ដែលមិនទាន់មានខ្សែចង្វាក់កែច្នៃ។ ម៉្យាងទៀត សកម្មភាពប្រកបដោយឆន្ទៈនិងការតម្រង់ទិសរបស់អាជ្ញាធរទទួលខុសត្រូវគឺជាការចាំបាច់ សំដៅធ្វើការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារដោយគិតគូរដល់ផលប៉ះពាល់ដែលកំពុងប្រឈម។





## ៥. ក្របខណ្ឌយុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍនេះ ស្នូលយុទ្ធសាស្ត្រចំនួន៦ ត្រូវបានលើកឡើងគឺ

១- ការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ។

២- ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរដែលកបនឹងដំណាំកៅស៊ូ។

៣- ការជំរុញការដាំដុះកៅស៊ូគ្រួសារ។

៤- ការជំរុញចម្ការកៅស៊ូឧស្សាហកម្មដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ។

៥- ការជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឲ្យបានល្អ។

៦- ការពង្រឹងតួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូនិងអភិបាលកិច្ច។

គំនូសបំព្រួញសន្ទិយោគរវាងយុទ្ធសាស្ត្រថ្នាក់ជាតិ គោលដៅ និងស្នូលយុទ្ធសាស្ត្រកៅស៊ូ មានដូចខាងក្រោម៖








ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា បានបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានកៅស៊ូ ជាមួយនឹងដៃគូដែលមានការពាក់ព័ន្ធ ដោយយកចិត្តទុកដាក់ជាសំខាន់ទៅលើបញ្ហាប្រឈមនានា និងដោយផ្តល់នូវភាពល្អប្រសើរនៅក្នុងការអភិវឌ្ឍវិស័យកៅស៊ូមួយប្រកបដោយនិរន្តរភាព។ ផែនការយុទ្ធសាស្ត្រនេះមានស្នូលយុទ្ធសាស្ត្រចំនួន៦ ដូចបានរៀបរាប់ជូនខាងលើរួមទាំងគោលដៅមួយចំនួនផង។





## ៥.១ យុទ្ធសាស្ត្រទី១៖ *ការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ*

### ៥.១.១ គោលបំណង

លើកកំពស់គុណភាពចម្ការកៅស៊ូគ្រប់ផ្នែក ជាពិសេសចម្ការកៅស៊ូគ្រួសារខ្នាតតូច និងមធ្យម ឱ្យទទួលបាននូវទិន្នផលខ្ពស់ ទាំងជ័រ ទាំងដើមកៅស៊ូ សំដៅជួយបង្កើនប្រាក់ចំណូលដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ និងការការពារបរិស្ថានធម្មជាតិ។

### ៥.១.២ បញ្ហាប្រឈម

កង្វះខាតក្នុងការកែលម្អគុណភាពរុក្ខសម្ភាររបស់ចម្ការកៅស៊ូគ្រួសារ អាចនឹងធ្វើឱ្យទិន្នផលជ័រកៅស៊ូចុះថយជាងទិន្នផលធម្មតា ដែលធ្វើឱ្យប្រទេសជាតិទទួលរងការខាតបង់ប្រាក់ចំណូលជាច្រើន។ ក្នុងរយៈពេល១៥ឆ្នាំទៅមុខដោយគិតពីឆ្នាំ២០១១តទៅ ផលិតផលកៅស៊ូដែលបានដាំដុះរួចហើយរបស់កសិករតូចតាចក្នុងចង្វាក់ ៥.០០០ហិកតា ក្នុងមួយឆ្នាំ (ដោយមិនគិតការដាំដុះរបស់ចម្ការកៅស៊ូកសិឧស្សាហកម្ម) នឹងបង្ហាញឱ្យឃើញនូវការបាត់បង់ក្នុងបរិមាណចំនួន១៦៥.០០០តោន។ ដូច្នេះ ការបាត់ចំណូលនេះ បើគិតជាតម្លៃវិញ គឺមានរហូតដល់៥៧៧,៥លានដុល្លារសហរដ្ឋសម្រាប់រយៈពេល១០ឆ្នាំក្រោយ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២៦ (លើមូលដ្ឋានថ្លៃ៣.៥០០ដុល្លារក្នុងមួយតោន) ដែលគិតជាមធ្យមគឺមានចំនួន៥៧,៧៥លានដុល្លារក្នុងមួយឆ្នាំ។

ការដាំដុះកៅស៊ូដោយប្រើរុក្ខសម្ភារមិនបានត្រឹមត្រូវ បានធ្វើឱ្យការថែទាំត្រូវចំណាយរយៈពេលយូរថែមទៀត និងការចំណាយវិនិយោគកាន់តែច្រើន។

ការដាំដុះ និងការថែទាំកៅស៊ូមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសបានផ្តល់នូវផលលំបាកជាច្រើន ដូចជា អត្រាងាប់នៃកូនកៅស៊ូច្រើន ការដុះលូតលាស់នៃដើមកៅស៊ូមិនស្មើគ្នា និងចុងក្រោយទិន្នផលជ័រកៅស៊ូចុះទាប។

### ៥.១.៣ សកម្មភាពជាអាទិភាព

- ពង្រីកសេវាណែនាំបច្ចេកទេសថ្នាក់ជាតិមួយឱ្យដល់ មូលដ្ឋានអ្នកដាំដុះកៅស៊ូ ។ សេវានេះអាចមានទ្រង់ទ្រាយខុសៗគ្នាទៅតាមប្រភេទនៃចម្ការកៅស៊ូដែលត្រូវជួយទ្រទ្រង់ ។ សម្រាប់ចម្ការកៅស៊ូគ្រួសារតូចតាចត្រូវមានក្របខ័ណ្ឌបច្ចេកទេសមួយធ្វើការដោយជិតស្និទ្ធនិងដោយគ្មានកម្រៃ។ សម្រាប់ចម្ការកៅស៊ូផ្សេងៗទៀតអាចមានសេវាណែនាំបច្ចេកទេសតាមការស្នើសុំរបស់ម្ចាស់ចម្ការ ដោយគិតកម្រៃ។





- រៀបចំយន្តការត្រួតពិនិត្យគុណភាពរុក្ខសម្ភារកៅស៊ូ ការធ្វើអត្តសញ្ញាណកម្ម និងវិញ្ញាបនកម្មថ្នាលពូជ និងការបណ្តុះបណ្តាលអ្នកធ្វើថ្នាលពូជទាំងអស់។ ការត្រួតពិនិត្យត្រូវមានបែបបទវិញ្ញាបនកម្មចាំបាច់សម្រាប់ថ្នាលពូជកៅស៊ូ។

- ធ្វើសុវត្ថិកម្មគុណភាពរុក្ខសម្ភារកៅស៊ូ ដើម្បីធានាគុណភាពក្នុងការដាំដុះ។

- ពង្រឹងនិងពង្រីកបន្ថែមទៀតនូវសមត្ថភាពជំនាញដល់មន្ត្រីអគ្គនាយកដ្ឋានកៅស៊ូក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការផលិតពូជកៅស៊ូថ្មីដែលអាចបន្សាំជាមួយបម្រែបម្រួលអាកាសធាតុ និងការបណ្តុះបណ្តាលបច្ចេកទេសដល់អ្នកដាំកៅស៊ូ។

## ៥.២ យុទ្ធសាស្ត្រទី២ ៖ *ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពលដីទំនេរដែលកបនឹងដំណាំកៅស៊ូ*

### ៥.២.១ គោលបំណង

សម្រួលដល់ការប្រើប្រាស់សក្តានុពលដី នៅក្នុងតំបន់ព្រៃឈើដែលរេចរិល ដោយប្រែក្លាយទៅជាតំបន់ចម្ការឈើដាំ (កៅស៊ូ អាកាស្យា ម៉ៃសាក់...) តាមរយៈការធ្វើអនុបយោគសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់រដ្ឋឱ្យទៅជាសម្បត្តិឯកជនរបស់រដ្ឋ ដោយការចុះពិនិត្យស្ថានភាពដីដែលត្រូវផ្តល់ជាសម្បទានសេដ្ឋកិច្ចឬសង្គមកិច្ចដល់អ្នកប្រើប្រាស់ជាវិនិយោគិន ជាសហគមន៍ ឬជាគ្រួសារ។

### ៥.២.២ បញ្ហាប្រឈម

រយៈកាលកន្លងមក តំបន់ព្រៃឈើមួយចំនួនធំកំពុងទទួលរងការកាប់បំផ្លាញ ក្នុងគោលបំណងយកឈើនិងដីធ្វើជាចម្ការដំណាំតូចតាច មធ្យម ឬធំ។ ការរំលោភបំពានសិទ្ធិនិងការទទួលខុសត្រូវលើបញ្ហាគ្រប់គ្រងព្រៃឈើ តែងតែកើតមានទំនាស់ ឬវិវាទជាញឹកញាប់ អាស្រ័យដោយភាពមិនច្បាស់លាស់នៃការកំណត់ព្រំប្រទល់ព្រៃឈើនិងចំណាត់ថ្នាក់ព្រៃឈើ។ ភាពមិនច្បាស់លាស់នៅក្នុងការកាន់កាប់ដីព្រៃឈើនិងសិទ្ធិរបស់អ្នកប្រើប្រាស់ដីមិនបានលើកទឹកចិត្តដល់អ្នកដែលមានការពាក់ព័ន្ធនានាឱ្យចូលរួមការពារព្រៃឈើប្រកបដោយចីរភាពឡើយ។ ស្ថានភាពនេះបានអូសបន្លាយពេលវេលាជាច្រើនឆ្នាំ ហើយអាចនឹងកើតមានជាបន្តទៀត ទោះបីជារាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលព្រៃឈើ និងអាជ្ញាធរពាក់ព័ន្ធបានខិតខំចូលរួមដោះស្រាយនិងការពារយ៉ាងណាក៏ដោយ។

តាមការសង្កេតរហូតមកដល់បច្ចុប្បន្ននេះចម្ការតូចៗ មធ្យម ឬធំមួយផ្នែកធំបានដាំឈើ ដូចជាអាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ កៅស៊ូ និងប្រភេទដំណាំផ្សេងៗទៀតសម្រាប់បម្រើទីផ្សារ។ ចម្ការកៅស៊ូខ្នាតតូច មធ្យម ឬ ធំ ដែលបង្កើតឡើងដោយបុគ្គលឬក្រុមឯកជន នៅក្នុងតំបន់ព្រៃឈើ ហាក់ដូចជាស្ថិតនៅក្រៅច្បាប់ ដោយសារមិនមានការទទួលស្គាល់និងអនុញ្ញាតត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច។





### ៥.២.៣ សកម្មភាពជាអាទិភាព

ដើម្បីដោះស្រាយភាពចម្រូងចម្រាស់និងដើម្បីកាត់បន្ថយទំនាស់ខាងលើ រដ្ឋចាំបាច់ត្រូវកំណត់ព្រំប្រទល់តំបន់ព្រៃឈើនិងធ្វើចំណាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទៅតាមមុខងារ និងសក្តានុពលពិតប្រាកដរបស់ព្រៃឈើ។

ទៅអនាគត ការអនុវត្តកម្មវិធីព្រៃឈើជាតិ២០១០-២០២៩ នឹងផ្តល់នូវចម្លើយជាវិជ្ជមានដល់ចម្ការឈើ ដូចជា អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងចម្ការដំណាំផ្សេងៗទៀត ជាពិសេសចម្ការកៅស៊ូដែលបានដាំដុះរួចហើយនៅក្នុងតំបន់ព្រៃឈើដែលរេចរិល។ ដូច្នេះ អគ្គនាយកដ្ឋានកៅស៊ូអាចចាត់ចែង៖

- ទំនាក់ទំនងស្វែងរកទិន្នន័យដែលពាក់ព័ន្ធដល់ការកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ និងការធ្វើបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដើម្បីធានានូវកម្មសិទ្ធិនិងសិទ្ធិប្រើប្រាស់របស់កសិករ ឬសមាគមក្នុងការរៀបចំបង្កើតជាចម្ការកៅស៊ូថ្មីៗនៅក្នុងតំបន់មិនមែនប្រពៃណី និងសិក្សាស្រាវជ្រាវបន្ថែមអំពី៖
  - ចម្ការកៅស៊ូគ្រួសារដែលស្ថិតនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចនិងសង្គមកិច្ច
  - សក្តានុពលដីដែលកបនឹងដំណាំកៅស៊ូស្ថិតក្នុងតំបន់ព្រៃឈើរេចរឹលឬស្ថិតនៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច ដែលរាជរដ្ឋាភិបាលបានផ្តល់ ឬដែលបានត្រៀមបម្រុងទុក។
- សម្របសម្រួលសកម្មភាពក្នុងការរៀបចំធ្វើប័ណ្ណកម្មសិទ្ធិដី នៅតំបន់ដែលមានសក្តានុពលសម្រាប់ដំណាំកៅស៊ូ ដើម្បីធានាសុវត្ថិភាពកម្មសិទ្ធិ កាត់បន្ថយជម្លោះ លើកទឹកចិត្តដល់ការធ្វើវិនិយោគ និងអាចប្រើប្រាស់ជាទ្រព្យបញ្ចាំ សម្រាប់ការខ្ចីឥណទានវិនិយោគបន្ថែម។

## ៥.៣ យុទ្ធសាស្ត្រទី៣៖ ការជំរុញដំណាំកៅស៊ូគ្រួសារ

### ៥.៣.១ គោលបំណង

ដំណាំកៅស៊ូមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ជាងដំណាំកសិកម្មដទៃទៀត។ នៅបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិធំៗ សមាមាត្រនៃចម្ការកៅស៊ូគ្រួសារបានគ្របដណ្តប់លើសពី៨០ ទៅ ៨៥ ភាគរយនៃផ្ទៃដីកៅស៊ូសរុប។ ចំណែកនៅកម្ពុជា លើមូលដ្ឋាននៃទិន្នន័យឆ្នាំ២០១០បានបង្ហាញថា ផ្ទៃដីដាំដុះកៅស៊ូគ្រួសារនិងឯកជនមានសមាមាត្រជាង៤៥ ភាគរយប៉ុណ្ណោះនៃផ្ទៃដីដាំដុះកៅស៊ូសរុប។ ផ្អែកលើទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គម ដំណាំកៅស៊ូគ្រួសារបានបង្ហាញអំពីផលប្រយោជន៍ពិតប្រាកដ បើប្រៀបធៀបជាមួយចម្ការកៅស៊ូកសិឧស្សាហកម្មដូចជាប្រាក់ចំណូលខ្ពស់ កម្លាំងពលកម្មសមស្រប សមត្ថភាពអាចទប់ទល់បាននៅពេលតម្លៃទីផ្សារកៅស៊ូចុះថោកដោយថាហេតុមានប្រាក់ចំណូលថេរ និងអាចបង្កើតជាទុនសម្រាប់អ្នកដាំកៅស៊ូផង។ តាមការពិនិត្យជាក់ស្តែងឃើញថា កសិករកម្ពុជាមានលទ្ធភាពក្នុងការពង្រីកផ្ទៃដីដាំដុះកៅស៊ូជាលក្ខណៈគ្រួសារបានច្រើនថែមទៀត។





ដូច្នេះ ស្នូលយុទ្ធសាស្ត្រនេះ មានគោលបំណងជួយបង្កើនជីវភាពរស់នៅរបស់កសិករតូចតាចនិងបង្កើតការងារនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការធ្វើចំណាកស្រុកនិងការចូលរួមការពារបរិស្ថាន។

### ៥.៣.២ បញ្ហាប្រឈម

- ការផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូនៅមានកម្រិត
- ចម្ការកៅស៊ូគ្រួសារមួយផ្នែកធំនៅមិនទាន់មានប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីនៅឡើយ ដែលធ្វើឱ្យកសិករគ្មានលទ្ធភាពខ្ចីឥណទានពីស្ថាប័នមីក្រូហិរញ្ញវត្ថុ
- ចម្ការកៅស៊ូមួយផ្នែកបានស្ថិតក្នុងដែនតម្របព្រៃឈើ ដែលមិនមានច្បាប់អនុញ្ញាត
- ចម្ការកៅស៊ូមួយផ្នែកតូចមិនមានបច្ចេកទេសគ្រប់គ្រាន់ និងច្បាស់លាស់ឡើយ (ដូចជា ការដាំដុះ ការថែទាំ ការប្រមូលផល ការទុកដាក់ផលិតផលជ័រកៅស៊ូ...)
- ចម្ការកៅស៊ូមួយផ្នែកតូចមិនបានប្រើប្រាស់រុក្ខសម្ភារដែលមានគុណភាពល្អ

### ៥.៣.៣ សកម្មភាពជាអាទិភាព

- ពង្រឹងក្របខ័ណ្ឌស្រាវជ្រាវ និងផ្សព្វផ្សាយ
- ជំរុញ និងបង្កើនការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយបច្ចេកទេស
- ស្រង់ និងចងក្រងស្ថិតិកៅស៊ូគ្រួសារ
- ស្វែងរកដៃគូសហការណ៍និងគាំទ្រថវិកាសម្រាប់ការងារអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ

## ៥.៤ យុទ្ធសាស្ត្រទី៤៖ ការជំរុញចម្ការកៅស៊ូកសិ-ឧស្សាហកម្ម ដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍកៅស៊ូគ្រួសារ

### ៥.៤.១ គោលបំណង

ស្នូលយុទ្ធសាស្ត្រនេះមានគោលបំណងជួយកសិករឬកម្មករដែលជាម្ចាស់ចម្ការកៅស៊ូគ្រួសារឱ្យទទួលបាននូវផលប្រយោជន៍ពីក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្មនៅលើដីសម្បទានសេដ្ឋកិច្ច រាប់តាំងពីបច្ចេកវិទ្យាក្នុងការបង្កើតចម្ការកៅស៊ូគ្រួសារ រហូតដល់ការកែច្នៃជ័រ ដោយរក្សាបាននូវផលប្រយោជន៍ទៅវិញទៅមក រវាងភាគីម្ចាស់ក្រុមហ៊ុននិងកសិករ ឬកម្មករ ឬក៏ម្ចាស់ចម្ការកៅស៊ូគ្រួសារ ។





### ៥.៤.២ បញ្ហាប្រឈម

- កសិករឬកម្មករមិនមានដីសម្រាប់ដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ
- ក្រុមហ៊ុនមិនបានគិតគូរដល់ការបង្កើតចម្ការកៅស៊ូគ្រួសារ ឬមិនចង់ឲ្យចម្ការកៅស៊ូគ្រួសារស្ថិតនៅជុំវិញចម្ការកៅស៊ូរបស់ខ្លួនឡើយ (ដោយខ្លាចកើតមានបាតុភាពលួចជ័រ)
- ទំនាក់ទំនងរវាងចម្ការកៅស៊ូកសិឧស្សាហកម្មនិងចម្ការកៅស៊ូគ្រួសារនៅមានកម្រិត ទាំងការផ្តល់សេវាបច្ចេកទេស ទាំងការផ្គត់ផ្គង់រុក្ខសម្ភារ
- ការផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់វិនិយោគដាំដុះកៅស៊ូ មិនបានគិតទៅដល់ការបែងចែកដីជាលក្ខណៈសម្បទានសង្គមកិច្ចដល់គ្រួសារកសិករឬកម្មករដែលស្ថិតនៅជុំវិញឡើយ
- កសិករខ្វះថវិកាសម្រាប់ការងារដាំដុះនិងថែទាំ។

### ៥.៤.៣ សកម្មភាពអាទិភាព

- ជំរុញក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្មជួយផ្តល់បច្ចេកវិទ្យាដល់ចម្ការកៅស៊ូគ្រួសារ សម្រាប់ជាផលប្រយោជន៍ទូទៅផងនិងបង្កើតជាប៉ូលទាក់ទាញសម្រាប់ការកែច្នៃជ័រកៅស៊ូគ្រួសារបន្ថែម នៅក្នុងតំបន់អភិវឌ្ឍដំណាំកៅស៊ូផង
- ចូលរួមក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចឲ្យដល់កសិករ សម្រាប់ដាំកៅស៊ូនៅក្នុងឬជុំវិញតំបន់ដីសម្បទានសេដ្ឋកិច្ចវិនិយោគដាំដុះកៅស៊ូ
- អគ្គនាយកដ្ឋានកៅស៊ូ ធ្វើជាអ្នកសម្របសម្រួលរវាងម្ចាស់ចម្ការកៅស៊ូកសិឧស្សាហកម្មនិងម្ចាស់កៅស៊ូគ្រួសារឯកជន ដើម្បី ៈ រកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាក្នុងវិស័យកៅស៊ូក្នុងការពង្រឹងនិងពង្រីកឧស្សាហកម្មកៅស៊ូនៅក្នុងតំបន់នីមួយៗ។

## ៥.៥ យុទ្ធសាស្ត្រទី៥ ៖ *ការជំរុញ និងបង្កើនខ្សែចង្វាក់តម្លៃកៅស៊ូឲ្យបានល្អ*

### ៥.៥.១ គោលបំណង

ធ្វើឱ្យផលិតផលជ័រកៅស៊ូកម្ពុជាមានតម្លៃខ្ពស់នៅលើទីផ្សារអន្តរជាតិ។

### ៥.៥.២ បញ្ហាប្រឈម

- ប្រព័ន្ធទីផ្សារផលិតផលកៅស៊ូក្នុងស្រុក និងក្រៅស្រុក មិនទាន់មានរបៀបរបបច្បាស់លាស់
- ទីផ្សារនាំចេញកៅស៊ូនៅចង្អៀត (មានតែទីផ្សារវៀតណាមមួយគត់ ក្រៅពីនោះគឺមានតិចតួច)








- ការលក់ជ័រកៅស៊ូរបស់កសិករនៅមានតម្លៃទាប បើប្រៀបធៀបនឹងតម្លៃលក់ជ័រកៅស៊ូរបស់កសិករនៅប្រទេសជិតខាង
- ការបង្កើតសមាគមកៅស៊ូគ្រួសារមិនទាន់បានទូលំទូលាយនៅទូទាំងប្រទេស (បច្ចុប្បន្នមានសមាគមកៅស៊ូគ្រួសារចំនួន៤ នៅក្នុងខេត្តកំពង់ចាម និងមិនទាន់មានសកម្មភាពនៅឡើយ)
- កង្វះខាតបច្ចេកទេសក្នុងការដាំដុះ ការប្រមូលផល ការកែច្នៃ និងការវេចខ្ចប់
- ថ្លៃដើមផលិតផលកៅស៊ូខ្ពស់ដោយសារ តម្លៃថាមពលកែច្នៃ និងថ្លៃដឹកជញ្ជូនមានថ្លៃខ្ពស់ នីតិវិធីនាំចេញនៅមានភាពស្មុគស្មាញ និងចំណាយក្រៅផ្លូវការច្រើន
- គុណភាពជ័រកៅស៊ូនៅមិនទាន់ធានាបានតាមលក្ខខណ្ឌទីផ្សារ។

### ៥.៥.៣ សកម្មភាពជាអាទិភាព

- សិក្សាលំអិតអំពីទីផ្សារសំខាន់ៗសម្រាប់ការនាំចេញផលិតផលកៅស៊ូកម្ពុជា
- បង្កើតមជ្ឈមណ្ឌលទីផ្សារផលិតផលកៅស៊ូ
- ជំរុញការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលកៅស៊ូ
- តាមដាន វិភាគ វាយតម្លៃ និងផ្សព្វផ្សាយស្ថានភាពទីផ្សារកៅស៊ូក្នុងនិងក្រៅប្រទេសតាមគ្រប់រូបភាព (ព្រឹត្តិបត្រ បណ្តាញព័តមាន គេហទំព័រ...)
- ពង្រឹងនិងពង្រីកសមាគមអ្នកដាំកៅស៊ូ ដើម្បីងាយស្រួលក្នុងការជួយទ្រទ្រង់បច្ចេកទេស ការលក់ដូរ ការរកទីផ្សារ និងជាខ្សែរយៈទាក់ទងជាប្រចាំជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអាជ្ញាធរពាក់ព័ន្ធ
- កែសម្រួលនិងពង្រឹងប្រព័ន្ធផ្តល់លិខិតអនុញ្ញាតសាងសង់រោងចក្រកែច្នៃជ័រកៅស៊ូ
- ជំរុញបច្ចេកទេសក្នុងការដាំដុះ ការប្រមូលផល ការកែច្នៃ និងការវេចខ្ចប់ ឱ្យកាន់តែប្រសើរ
- ជំរុញការអនុវត្តប្រព័ន្ធវិញ្ញាបនប័ត្របញ្ជាក់គុណភាពកៅស៊ូតាមស្តង់ដារអន្តរជាតិ។
- ទាក់ទាញវិនិយោគិនក្នុងស្រុក និងបរទេស ក្នុងការបង្កើតរោងចក្រឬកម្មន្តសាល ដើម្បីផលិតវត្ថុឬទំនិញចេញពីជ័រនិងឈើកៅស៊ូ (Rubber-base Products)។





## ៥.៦ យុទ្ធសាស្ត្រទី៦ ៖ *ការពង្រឹងតួនាទីដឹកនាំរបស់អគ្គនាយកដ្ឋានកៅស៊ូ និងអភិបាលកិច្ច*

### ៥.៦.១ គោលបំណង

ពង្រឹងនិងកែលម្អតួនាទីភារកិច្ចអគ្គនាយកដ្ឋានកៅស៊ូឲ្យទៅជាអង្គភាពគ្រប់គ្រងនិងដឹកនាំ ប្រកបដោយថាមភាពនិងភាពរលូន ដើម្បីឆ្លើយតបចំពោះតម្រូវការនិងការពេញចិត្តគ្រប់តួអង្គកៅស៊ូ។

ជំរុញនិងអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិកម្ពុជា និងអភិវឌ្ឍន៍គោលដៅជាតិ គោលនយោបាយ និងអាទិភាពសម្រាប់ការអភិវឌ្ឍនិងការគ្រប់គ្រងឧស្សាហកម្មកៅស៊ូធម្មជាតិកម្ពុជា ដើម្បីឲ្យក្លាយទៅជាប្រទេសផលិតកៅស៊ូមួយនៅក្នុងចំណោមបណ្តាប្រទេសផលិតកៅស៊ូក្នុងពិភពលោក។

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានកៅស៊ូគឺជាអង្គភាពទទួលខុសត្រូវលើវិស័យកៅស៊ូ ស្ថិតនៅក្រោមចំណុះក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានជំនាញចំនួនប្រាំនិងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមួយ(អនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨)។

ដូចបានរៀបរាប់នៅក្នុងសេចក្តីផ្តើមខាងលើ ដើម្បីធ្វើឱ្យមានសុខដុមនីយកម្មក្នុងការអនុវត្តវិធានការឆ្លើយតបចំពោះយុទ្ធសាស្ត្រខាងលើ ចាំបាច់ត្រូវប្រែក្លាយអគ្គនាយកដ្ឋានកៅស៊ូឱ្យទៅជាអង្គភាពសម្របសម្រួលមួយ។ អង្គភាពសម្របសម្រួលថ្មីនេះ ត្រូវមានសិទ្ធិអំណាច មធ្យោបាយបំពេញការងារ ធនធានមនុស្ស និងប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់បំពេញភារកិច្ចយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍវិស័យកៅស៊ូ ជាពិសេសភារៈកិច្ចដឹកនាំដាច់ដោយឡែកនូវសកម្មភាពជំរុញចម្ការកៅស៊ូគ្រួសារខ្នាតតូច និងមធ្យម និងអាចធ្វើឱ្យរលូននូវការអនុវត្តវិធានការទាំងឡាយ។ ម្យ៉ាងទៀត ដើម្បីឆ្លើយតបចំពោះស្នូលយុទ្ធសាស្ត្រខាងលើ ចាំបាច់ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូសម្រាប់ធានាការគ្រប់គ្រងនិងជំរុញការអភិវឌ្ឍឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា ចាប់តាំងពីផ្នែកលំហូរខាងលើ (upstream) ផ្នែកលំហូរកណ្តាល (midstream) និងផ្នែកលំហូរខាងក្រោម (downstream)។





## ៥.៦.២ បញ្ហាប្រឈម

- ការងារគ្រប់គ្រងនៅមិនទាន់បានល្អ ដោយខ្វះលិខិតបទដ្ឋានគតិយុត្តិក្រោមច្បាប់និងច្បាប់
- ថវិកាសម្រាប់ដំណើការនៅមានកម្រិត ដែលធ្វើឱ្យការគ្រប់គ្រង ការត្រួតពិនិត្យ និងផ្សព្វផ្សាយបច្ចេកទេសមិនបានសកម្មនិងទូលំទូលាយ
- មិនទាន់មានរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ដែលជាប្រភពព័ត៌មាន ទិន្នន័យនិងស្ថិតិកៅស៊ូ និងតម្រូវការរបស់កសិករក្នុងការបណ្តុះបណ្តាលការងារបច្ចេកទេសកៅស៊ូ។

## ៥.៦.៣ សកម្មភាពអាទិភាព

- កសាងក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងការអភិវឌ្ឍធនធានមនុស្ស សម្រាប់អភិវឌ្ឍកៅស៊ូ ដើម្បីជាផលប្រយោជន៍ដល់អ្នកដាំ
- ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ
- ស្វែងរកនិង កៀរគរប្រភពថវិកា ដើម្បីជំរុញការអភិវឌ្ឍវិស័យកៅស៊ូ
- ចាត់តាំងមន្ត្រីជំនាញនៅតាមមាត់ច្រកនាំចេញ ដើម្បីតាមដាននិងត្រួតពិនិត្យសកម្មភាពនាំចេញនាំចូលផលិតផលកៅស៊ូ រុក្ខសម្ភារ ឧបករណ៍ និងគ្រឿងចក្រសម្រាប់បម្រើវិស័យកៅស៊ូ
- ធ្វើជាអាជ្ញាកណ្តាលនៅក្នុងដំណោះស្រាយប្រកបដោយសមធម៌ក្នុងការទិញ-លក់ ការកែច្នៃជ័រ
- បង្កើតការិយាល័យដំណាំកៅស៊ូនៅតាមបណ្តាខេត្ត ដើម្បីសិក្សាអំពីសក្តានុពលដីដែលកបនឹងដំណាំកៅស៊ូ តាមដាន ត្រួតពិនិត្យ រៀបចំការចុះបញ្ជី ប្រមូលទិន្នន័យ ចងក្រងស្ថិតិកៅស៊ូ និងផ្ទេរបច្ចេកវិទ្យា ព្រមទាំងផ្តល់ព័ត៌មានកៅស៊ូឱ្យដល់អ្នកពាក់ព័ន្ធនឹងវិស័យកៅស៊ូបានទាន់ពេលវេលា និងមានប្រសិទ្ធិភាព។







## ៦. សេចក្តីសន្និដ្ឋាន

ឧស្សាហកម្មកៅស៊ូធម្មជាតិបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយ បង្កើនប្រាក់ចំណូលទៀងទាត់ដល់អ្នកដាំកៅស៊ូ ដល់សេដ្ឋកិច្ចជាតិ ការបង្កើតអាជីពនៅមូលដ្ឋានជនបទ ចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តរភាព។ ដើម្បីឲ្យយុទ្ធសាស្ត្រនេះអាចសម្រេចជោគជ័យបាន អគ្គនាយកដ្ឋានកៅស៊ូត្រូវការចាំបាច់នូវការជួយគាំទ្រ ទាំងស្មារតី ទាំងសម្ភារៈ និងទាំងថវិកាពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពីរាជរដ្ឋាភិបាលកម្ពុជា និងពីដៃគូអភិវឌ្ឍន៍នានាជាជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ដើម្បី បង្កើនសមត្ថភាពធនធានមនុស្ស ការស្រាវជ្រាវ និងការអភិវឌ្ឍដំណាំកៅស៊ូ។

ដោយច្បាប់ស្តីពីកៅស៊ូ ជាមូលដ្ឋានគ្រឹះដ៏ចំបងក្នុងការធ្វើឲ្យសម្រេចយុទ្ធសាស្ត្រនេះ ដៃគូអភិវឌ្ឍន៍នានា គួរពិនិត្យលទ្ធភាពផ្តល់ និងបន្តផ្តល់ជំនួយបច្ចេកទេសដល់អគ្គនាយកដ្ឋានកៅស៊ូដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូមួយ ដែលមានលក្ខណៈសមស្របនឹងស្ថានភាពជាក់ស្តែងនៅកម្ពុជា។ ច្បាប់នេះនឹងបរិយាយច្បាស់លាស់ពីមុខងារ តួនាទី សិទ្ធិអំណាច រចនាសម្ព័ន្ធ ប្រភពថវិកា និងមានស្វ័យភាពហិរញ្ញវត្ថុសម្រាប់ការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងកៅស៊ូនៅកម្ពុជា។

សមិទ្ធផលដែលត្រូវសម្រេចឱ្យបាន និងការត្រួតពិនិត្យអំពីវឌ្ឍនភាពនៃការអនុវត្តន៍តាមចំណុចគោលដៅសូចនាករឬលទ្ធផលរំពឹងទុក និងថវិកា បានរៀបរាប់នៅក្នុងតារាងម៉ាទ្រីសក្នុង *ឧបសម្ព័ន្ធទី៤*។ យុទ្ធសាស្ត្រ និងចំណុចគោលដៅដែលបានរៀបចំឡើងនឹងត្រូវធ្វើការពិនិត្យវាយតម្លៃឡើងវិញសម្រាប់រយៈពេល៣ឆ្នាំម្តង ៥ឆ្នាំម្តង និងជាបន្តបន្ទាប់ស្របតាមអាណត្តិរបស់រាជរដ្ឋាភិបាល។









ឧបសម្ព័ន្ធទី ១

# ស្ថិតិផ្ទៃដី ផលិតផល និងទិន្នផលកៅស៊ូ ឆ្នាំ១៩២១-១៩៦៧

| ឆ្នាំ | ផ្ទៃដីកៅស៊ូ (ហិកតា) | | | ផលិតផល | ទិន្នផលមធ្យម | នីហរណកម្ម |
|---|---|---|---|---|---|---|
| | ដាំដុះ | មិនទាន់ឲ្យផល | ឲ្យផល | (តោន) | (គ.ក/ហិកតា) | (តោន) |
| 1921-22 | 1,224 | 1,224 | 0 | 0 | 0 | |
| 1923 | 1,928 | 1,928 | 0 | 0 | 0 | |
| 1924 | 2,884 | 2,884 | 0 | 0 | 0 | |
| 1925 | 5,723 | 5,723 | 0 | 0 | 0 | |
| 1926 | 8,114 | 8,114 | 0 | 0 | 0 | |
| 1927 | 10,923 | 10,923 | 0 | 0 | 0 | |
| 1928 | 15,286 | 14,086 | 1,200 | 196 | 163 | |
| 1929 | 18,542 | 16,742 | 1,800 | 340 | 189 | |
| 1930 | 22,959 | 21,159 | 1,800 | 482 | 268 | |
| 1931 | 25,618 | 21,118 | 4,500 | 698 | 155 | |
| 1932 | 26,218 | 20,618 | 5,600 | 1,570 | 280 | |
| 1933 | 26,218 | 18,518 | 7,700 | 2,265 | 294 | |
| 1934 | 26,436 | 13,236 | 13,200 | 3,288 | 249 | |
| 1935 | 26,441 | 5,862 | 20,579 | 6,496 | 316 | |
| 1936 | 26,441 | 2,787 | 23,654 | 10,147 | 429 | |
| 1937 | 26,469 | 2,019 | 24,450 | 13,715 | 561 | |
| 1938 | 26,667 | 1,749 | 24,918 | 15,278 | 613 | |
| 1939 | 28,005 | 2,804 | 25,201 | 17,327 | 687 | |
| 1940 | 27,977 | 1,970 | 26,007 | 19,988 | 768 | |
| 1941 | 28,085 | 2,278 | 25,807 | 20,821 | 807 | |
| 1942 | 28,094 | 2,287 | 25,807 | 21,492 | 833 | |
| 1943 | 28,264 | 2,757 | 25,507 | 21,616 | 847 | |
| 1944 | 30,184 | 5,472 | 24,712 | 18,346 | 742 | |
| 1945 | 29,922 | 6,235 | 23,687 | 4,552 | 192 | |
| 1946 | 30,207 | 11,587 | 18,620 | 6,563 | 352 | |
| 1947 | 30,240 | 10,514 | 19,726 | 13,212 | 670 | |
| 1948 | 30,225 | 10,037 | 20,188 | 16,335 | 809 | |
| 1949 | 30,281 | 10,061 | 20,220 | 15,616 | 772 | |
| 1950 | 30,386 | 8,207 | 22,179 | 15,295 | 690 | |
| 1951 | 30,397 | 7,103 | 23,294 | 15,631 | 671 | |
| 1952 | 30,681 | 5,499 | 25,182 | 18,432 | 732 | 16,284 |
| 1953 | 30,721 | 4,181 | 26,540 | 22,388 | 844 | 21,074 |
| 1954 | 31,271 | 3,559 | 27,712 | 24,127 | 871 | 30,014 |
| 1955 | 31,536 | 2,548 | 28,988 | 27,848 | 961 | 29,258 |
| 1956 | 32,432 | 4,035 | 28,397 | 32,094 | 1,130 | 29,813 |
| 1957 | 34,398 | 5,996 | 28,402 | 31,684 | 1,116 | 34,794 |
| 1958 | 36,053 | 7,466 | 28,587 | 33,621 | 1,176 | 37,347 |
| 1959 | 37,905 | 9,316 | 28,589 | 34,468 | 1,206 | 38,283 |
| 1960 | 41,644 | 13,220 | 28,424 | 37,109 | 1,306 | 40,466 |
| 1961 | 47,691 | 18,937 | 28,754 | 39,980 | 1,390 | 35,957 |
| 1962 | 51,794 | 22,987 | 28,807 | 41,559 | 1,443 | 36,220 |
| 1963 | 54,524 | 24,527 | 29,997 | 40,755 | 1,359 | 42,168 |
| 1964 | 56,048 | 25,143 | 30,905 | 45,760 | 1,481 | 47,605 |
| 1965 | 59,050 | 25,893 | 33,157 | 48,959 | 1,477 | 45,378 |
| 1966 | 62,211 | 26,748 | 35,463 | 51,350 | 1,448 | 50,782 |
| 1967 | 64,054 | 24,907 | 39,147 | 53,716 | 1,372 | 47,655 |

*ប្រភព: សមាគមអ្នកដាំកៅស៊ូ សូណិចស៊ីម ឆ្នាំ១៩៦៧*







## ស្ថិតិផ្ទៃដី ផលិតផល និងទិន្នផលកៅស៊ូ ឆ្នាំ ១៩៨០-២០១០

| ឆ្នាំ | ផ្ទៃដី (ហិកតា) | | | ផលិតផល | ទិន្នផលមធ្យម | នីហរណកម្ម |
|---|---|---|---|---|---|---|
| | ដាំដុះ | មិនទាន់ឲ្យផល | ឲ្យផល | (តោន) | (គ.ក/ហ.ត) | (តោន) |
| 1980 | 5,000 | 0 | 5,000 | 1,300 | 260 | 1,454 |
| 1981 | 8,800 | 0 | 8,800 | 4,000 | 450 | 2,616 |
| 1982 | 11,800 | 0 | 11,800 | 7,000 | 590 | 8,000 |
| 1983 | 14,546 | 0 | 14,546 | 9,000 | 610 | 10,021 |
| 1984 | 19,506 | 0 | 19,506 | 13,388 | 680 | 13,307 |
| 1985 | 26,300 | 0 | 26,300 | 17,645 | 490 | 16,421 |
| 1986 | 35,779 | 0 | 35,779 | 24,497 | 680 | 23,280 |
| 1987 | 40,000 | 0 | 40,000 | 24,917 | 620 | 26,335 |
| 1988 | 41,500 | 0 | 41,500 | 31,380 | 750 | 29,968 |
| 1989 | 46,789 | 0 | 46,789 | 33,645 | 710 | 33,727 |
| 1990 | 51,160 | 38 | 51,122 | 34,700 | 680 | 25,563 |
| 1991 | 51,670 | 100 | 51,570 | 35,000 | 670 | 24,807 |
| 1992 | 50,835 | 126 | 50,709 | 28,364 | 550 | 26,645 |
| 1993 | 43,545 | 211 | 43,334 | 22,345 | 510 | 20,990 |
| 1994 | 42,817 | 241 | 42,576 | 30,585 | 710 | 30,742 |
| 1995 | 45,048 | 525 | 44,523 | 35,427 | 800 | 34,413 |
| 1996 | 45,538 | 1,138 | 44,400 | 43,891 | 990 | 41,607 |
| 1997 | 44,466 | 967 | 43,499 | 43,503 | 1,000 | 44,799 |
| 1998 | 42,625 | 1,161 | 41,464 | 41,398 | 1,000 | 39,966 |
| 1999 | 38,413 | 1,055 | 37,358 | 44,043 | 1,180 | 43,221 |
| 2000 | 53,722 | 11,024 | 42,698 | 42,007 | 980 | 40,066 |
| 2001 | 51,458 | 13,778 | 37,680 | 38,562 | 1,020 | 35,672 |
| 2002 | 55,582 | 18,809 | 36,773 | 32,384 | 880 | 36,774 |
| 2003 | 53,527 | 19,831 | 33,696 | 32,382 | 960 | 32,764 |
| 2004 | 54,209 | 22,619 | 31,590 | 33,770 | 1,060 | 33,558 |
| 2005 | 60,406 | 30,004 | 30,402 | 29,464 | 960 | 29,950 |
| 2006 | 69,994 | 37,604 | 32,390 | 32,077 | 990 | 31,184 |
| 2007 | 82,059 | 51,568 | 30,491 | 32,975 | 1,080 | 33,121 |
| 2008 | 108,510 | 74,197 | 34,313 | 37,050 | 1,080 | 36,000 |
| 2009 | 129,920 | 95,785 | 34,135 | 37,380 | 1,095 | 36,500 |
| 2010 | 181,433 | 143,027 | 38,406 | 422,466 | 1,100 | 45,000 |

*ប្រភព: អគ្គនាយកដ្ឋានកៅស៊ូ*





ឧបសម្ព័ន្ធទី ៣

## តារាងប៉ាន់ស្មានផ្ទៃដីដាំដុះកៅស៊ូ ឆ្នាំ២០១១-២០២០

| ល.រ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ឆ្នាំដាំ | | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | |
| ១ | កសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ) | ហិកតា | 47.092 | 500 | 500 | 500 | 500 | 500 | 500 | 500 | 500 | 500 | 500 | 52.092 |
| ២ | កសិឧស្សាហកម្ម (ដីសម្បទានសេដ្ឋកិច្ច) | ហិកតា | 52.528 | 10.000 | 10.000 | 10.000 | 10.000 | 8.000 | 8.000 | 8.000 | 8.000 | 7.000 | 7.000 | 138.528 |
| ៣ | កៅស៊ូគ្រួសារ និងឯកជន | ហិកតា | 81.813 | 4.000 | 4.000 | 4.000 | 3.000 | 3.000 | 2.000 | 2.000 | 2.000 | 2.000 | 2.000 | 109.813 |
| | **សរុប** | **ហិកតា** | **181.433** | **14.500** | **14.500** | **14.500** | **13.500** | **11.500** | **10.500** | **10.500** | **10.500** | **9.500** | **9.500** | **300.433** |
| | **សរុបដល់ឆ្នាំ** | **ហិកតា** | **181.433** | **195.933** | **210.433** | **224.933** | **238.433** | **249.933** | **260.433** | **270.933** | **281.433** | **290.933** | **300.433** | |





***ឧបសម្ព័ន្ធទី ៤***

# តារាងម៉ាទ្រីស

## ផែនការសកម្មភាពជាអាទិភាព និងថវិកាក្នុងការអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកៅស៊ូធម្មជាតិនៅកម្ពុជា ឆ្នាំ ២០១១-២០២០

| ចក្ខុវិស័យ | យុទ្ធសាស្ត្រ | គោលដៅ/ទិសដៅ | ពេលវេលា (២០១១-២០២០) | | | | | | | | | | សកម្មភាព/សូចនាករ/លទ្ធផលរំពឹងទុក | ថវិកាគ្រោង (ដុល្លារ) | អង្គភាពទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | | | |
| ប្រែក្លាយឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជាប្រកបដោយផលិតភាពខ្ពស់ | ១.ធានាគុណភាពនិងផលិតភាពនៃការដាំដុះកៅស៊ូ | - លើកកម្ពស់គុណភាពចម្ការកៅស៊ូគ្រប់ផ្នែកជាពិសេសចម្ការកៅស៊ូគ្រួសារខ្នាតតូចនិងមធ្យមឱ្យទទួលបាននូវទិន្នផលខ្ពស់ទាំងជ័រ ទាំងដើមកៅស៊ូ សំដៅជួយបង្កើនប្រាក់ចំណូលដល់អ្នកដាំ ដល់សេដ្ឋកិច្ចជាតិ និងការការពារបរិស្ថានធម្មជាតិ | x | X | x | x | x | X | x | x | X | x | - ចុះផ្សព្វផ្សាយបច្ចេកទេស៣០ដង/១៥ខេត្ត/ឆ្នាំ<br>+ កសិករចំនួន៣០០០ នាក់ជារៀងរាល់ឆ្នាំទទួលបាន នូវចំណេះ ដឹងពីការដាំដំណាំកៅស៊ូ និងក្លូនកៅស៊ូមានទិន្នផលខ្ពស់នឹងត្រូវបានដាំដុះ ដែលមានការថែទាំប្រកបដោយប្រសិទ្ធភាព ។<br>- ផ្សព្វផ្សាយតាម បណ្តាញព័ត៌មាន÷<br>+ តាមទូរទស្សន៍ ៦ខែម្តង<br>+ តាមវិទ្យុ ៤ខែម្តង | ១៥០.០០០<br><br><br><br><br><br>៥០.០០០<br>១៥.០០០ | ន.អក |





| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | x | X | x | x | x | X | X | x | X | x | - ត្រួតពិនិត្យនិងផ្តល់ វិញ្ញាបនបត្រច្បារពូជ ២០ដង/ឆ្នាំ ច្បារពូជ ចំនួន១០០បានផ្តល់ វិញ្ញាបនបត្រច្បារពូជ និង<br>- បណ្តុះបណ្តាលអ្នកធ្វើច្បារពូជ៤ដង/ ឆ្នាំ ចំនួន ២៥នាក់/ ដង ។ | ១៧៥.០០០<br><br>៧០.០០០ | វសកក |
| | | | x | X | x | x | x | X | X | x | X | x | - ចុះត្រួតពិនិត្យថ្នាល កូន៣០ដង/ឆ្នាំ ថ្នាលបណ្តុះកូនកៅស៊ូ ចំនួន២០០បានធ្វើការត្រួតពិនិត្យ<br>- បណ្តុះ បណ្តាលអ្នកធ្វើថ្នាល កូន ១០ដង/ឆ្នាំ ចំនួន២៥នាក់/ ដង | ១២៥.០០០ | នអក |
| | | | x | X | x | x | x | X | X | x | x | x | - ចូលរួមវគ្គបណ្តុះ បណ្តាលក្រៅប្រទេស ៥ដង/ឆ្នាំ, ៥នាក់/ ដង ដើម្បីទទួលបានរបកគំហើញនិងបទពិសោធន៍ថ្មីនូវ÷<br>+ ពូជមានទិន្នផលខ្ពស់<br>+ ពូជបន្សាំបាននឹងបរិយាកាស<br>- ធ្វើច្បារបង្កាត់ពូជ ដែលមានទិន្នផលខ្ពស់និងបន្សាំ បាននឹង បរិយាកាសចំនួន៤ហិកតា/៥មេបា | ១៣៥.០០០<br><br>៨០០.០០០ | ន.អក<br><br>វសកក |
| | ២.ការសិក្សាអំពីលទ្ធភាពប្រើប្រាស់ដោយស្របច្បាប់នូវសក្តានុពល | -សម្រួលដល់ការប្រើប្រាស់សក្តានុពលដី នៅក្នុងតំបន់ព្រៃឈើដែលរេចរិល ដោយប្រែក្លាយទៅជាតំបន់ចម្ការ | X | X | X | X | X | X | X | X | X | X | - ចុះស្រាវជ្រាវស្ថិតិ ចម្ការកៅស៊ូស្ថិតក្នុង÷<br>+ ដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច និង តំបន់ព្រៃឈើរិចរិល<br>+ ៣០ដង/ឆ្នាំ/១៥ខេត្ត ចម្ការកៅស៊ូគ្រួសារ ប្រមាណ ២០.០០០ ហិកតាត្រូវបានស្រង់ | ៤៨.០០០ | ន.អក |





| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **ដីទំនេរ ដែលកបនឹង ដំណាំកៅស៊ូ** | ឈើដាំ (កៅស៊ូ អាកាស្យា ម៉ៃសាក់...) តាមរយៈការធ្វើអនុបយោគសម្បត្តិព្រៃឈើអចិន្ត្រៃយ៍របស់រដ្ឋឱ្យទៅជាសម្បត្តិឯកជនរបស់រដ្ឋ ដោយការចុះពិនិត្យស្ថានភាពដីដែលត្រូវផ្តល់ជាសម្បទានសេដ្ឋកិច្ចឬសង្គមកិច្ចដល់អ្នកប្រើប្រាស់ជាវិនិយោគិន ជាសហគមន៍ ឬ ជាគ្រួសារ។ | | | | | | | | | | | | | |
| | | | x | X | x | x | x | x | X | x | x | X | + ចុះសម្របសម្រួល និងជំរុញការផ្តល់ប័ណ្ណកម្មសិទ្ធ ២០ដង/ឆ្នាំ/១៥ខេត្ត, ២០០ប័ណ្ណ/ឆ្នាំបានផ្តល់ | ៤៨.០០០ | ន.អក និង ន.រន |
| | | | | | | | | | | | | | | | |





| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **៣.ការជំរុញដំណាំកៅស៊ូគ្រួសារ** | -ជួយបង្កើនជីវភាពរស់នៅរបស់កសិករតូចតាច និងបង្កើតការងារនៅជនបទ រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការធ្វើចំណាកស្រុក និងការចូលរួមការពារបរិស្ថាន។ | X | X | x | x | x | x | X | x | x | X | មន្ត្រីបង្គោលចំនួន៤៥ នាក់/១៥ខេត្ត ត្រូវបានធ្វើការបណ្តុះបណ្តាល និងផ្សព្វផ្សាយបន្ត | ៧០.០០០ | ន.អក<br>និង<br>ន.រន |
| | | | X | X | x | x | x | x | x | x | x | x | - ចុះបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូ១៥ខេត្ត១ខេត្ត២ដង<br>- អ្នកដាំកៅស៊ូ ១៥ខេត្ត ១ខេត្ត២ដង ១ដងកសិករចូលរួម ៧០នាក់ | ៧២.០០០<br><br><br>៣៦០.០០០ | ន.អក<br>និង<br>ន.កផក |
| | | | X | X | x | | | | | | | | - ផ្ទៃដីដំណាំកៅស៊ូ គ្រួសារ ចំនួន៨០០០០ ហិកតា ត្រូវបានស្រង់ | ១៧៥.០០០ | ន.អក |
| | | | x | X | x | x | x | x | x | x | X | x | - ចូលរួមក្នុងវេទិកា កៅស៊ូទាំងក្នុងនិងក្រៅប្រទេស ដើម្បីទាក់ទាញដៃគូសហប្រតិបត្តិការ និងគាំទ្រផ្តល់ថវិកា÷<br>+ ក្នុងស្រុក១ឆ្នាំ១ដង<br>+ ក្រៅស្រុក១ឆ្នាំ១ដង | <br><br>១៥.០០០<br>២៩៤.០០០ | ន.អក<br>និង<br>ន.ទសអ |
| | **៤.ការជំរុញចម្ការកៅស៊ូកសិឧស្សា** | - ជួយកសិករឬកម្មករដែលជាម្ចាស់ចម្ការកៅស៊ូគ្រួសារ | X | X | x | x | x | x | x | x | x | x | - ចុះពិនិត្យ និងណែនាំម្ចាស់ចម្ការកៅស៊ូ កសិស្សាហកម្ម ឱ្យជួយគាំទ្រដល់ម្ចាស់ចម្ការកៅស៊ូ គ្រួ សារ<br>+ ២ដង/ខេត្ត/១៥ខេត្ត | ៩៦.០០០ | ន.រន |





| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ហ កម្មដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍចម្ការកៅស៊ូគ្រួសារ | ឲ្យទទួលបាននូវផលប្រយោជន៍ពីក្រុមហ៊ុនចម្ការកៅស៊ូ កសិឧស្សាហកម្មនៅលើដីសម្បទានសេដ្ឋកិច្ច រាប់តាំងពីបច្ចេកវិទ្យាក្នុងការបង្កើតចម្ការកៅស៊ូគ្រួសារ រហូតដល់ការកែច្នៃជ័រ ដោយរក្សាបាននូវផលប្រយោជន៍ទៅវិញទៅមករវាងភាគីម្ចាស់ក្រុមហ៊ុននិងកសិករ ឬកម្មករ ឬក៏ម្ចាស់ចម្ការកៅស៊ូគ្រួសារ | | | | | | | | | | | | | |
| | | | X | X | x | x | x | x | x | x | X | x | - ចូលរួមក្នុងការផ្ដល់ដីសម្បទានសង្គមកិច្ចសម្រាប់ដំណាំកៅស៊ូដល់កសិករ<br>+ ក្នុង ១ឆ្នាំ ១០ដង | ៣២.០០០ | ន.អក |
| | | | x | X | x | x | X | x | x | x | X | x | - បញ្ហាប្រឈមមួយចំនួនត្រូវបានដោះស្រាយ ប្រជុំ១ឆ្នាំ៤ដង ១ដង៥០នាក់ចូលរួម | ១០៥.០០០ | ន.រន |





| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **៥.ការជំរុញ និងបង្កើនខ្សែចង្វាក់ តម្លៃកៅស៊ូឱ្យបានល្អ** | - ធ្វើឱ្យផលិតផលជ័រកៅស៊ូ កម្ពុជា មានតម្លៃខ្ពស់នៅលើទីផ្សារអន្តរជាតិ | X | X | X | X | X | X | X | X | X | X | - សិក្សាលំអិតអំពីទីផ្សារគោលដៅសំខាន់ៗ របស់ផលិតផលកៅស៊ូកម្ពុជា<br>+ ចូលរួមសិក្ខាសាលាស្តីពីទីផ្សារ<br>ក. ក្នុងស្រុក<br>ខ. ក្រៅស្រុក | <br><br><br>២.៤០០<br>៣៦.០០០ | ន.ទសអ |
| | | | X | X | X | X | X | X | X | X | X | X | - បង្កើតមជ្ឈមណ្ឌលទីផ្សារផលិតផលកៅស៊ូ<br>+ ចូលរួមចងក្រងក្រុមកសិករ<br>+ បណ្តុះបណ្តាលក្រុមកសិករអំពីទីផ្សារ | <br>១៣.៥០០<br>១៣.៥០០ | ន.ទសអ |
| | | | X | X | X | X | X | X | X | X | X | X | - ជំរុញការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលកៅស៊ូ<br>+ រៀបចំថតនិងផ្សាយពាណិជ្ជកម្មតាមវិទ្យុនិងទូរទស្សន៍<br>+ រៀបចំពិព័ណពាណិជ្ជកម្ម<br>ក. ក្នុងស្រុក<br>ខ. ក្រៅស្រុក | <br>៣២.៩០០<br><br>៤.០០០<br>៦០.០០០ | ន.ទសអ |
| | | | x | X | x | X | X | x | x | x | x | X | - កសិករទទួលបានព័ត៌មានពីការផ្គត់ផ្គង់តម្រូវការ និងតម្លៃកៅស៊ូប្រចាំថ្ងៃ<br>+ តាមវិទ្យុ និងទូរទស្សន៍ប្រចាំថ្ងៃ,៣២៩ ថ្ងៃ/ ឆ្នាំ<br>- បោះពុម្ពព្រឹត្តិបត្រកៅស៊ូប្រចាំខែ, មួយខែ២០០ច្បាប់<br>+ ១ច្បាប់ 5 ដុល្លា រ<br>+ បកប្រែ១០ដុល្លា រ/ទំព័រ, មួយច្បាប់៥ទំព័រ | <br><br>៣២.៩០០<br><br>១២០.០០០<br>៦.០០០ | ន.ទសអ |





| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | X | X | X | X | X | X | X | X | X | X | - ចុះពង្រឹងសមាគមអ្នកដាំកៅស៊ូគ្រួសារ១ឆ្នាំ ៥ដង<br>- ចុះជួយរៀបចំចងក្រងសមាគមអ្នកដាំកៅស៊ូ<br>+ សមាគមអ្នកដាំកៅស៊ូគ្រួសារចំនួន១០ក្នុង១ឆ្នាំ ត្រូវបានបង្កើត | ២៥.០០០ | ន.អក និង ន.ទសអ |
| | | | x | X | x | X | X | x | x | x | x | X | - ចុះពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់រោងចក្រកែច្នៃផលិតផលកៅស៊ូ<br>+ ១ឆ្នាំចុះពិនិត្យ ១ខេត្ត/ម្តង/១៥ខេត្ត<br>+ រោងចក្រចំនួន ៣០ត្រូវបានចុះបញ្ជី<br>- ចុះពិនិត្យទីតាំងសុំសាងសង់ និងតម្លើងរោងចក្រ-សិប្បកម្មកែច្នៃផលិតផលកៅស៊ូថ្មីដែលត្រូវបង្កើត ១ឆ្នាំ ២០ដង/១៥ខេត្ត | ៣៦.០០០<br><br>៤៨.០០០ | ន.កផក |
| | | | x | X | x | X | X | x | x | x | x | X | - ចុះពិនិត្យនិងផ្សព្វផ្សាយបច្ចេកទេសកែច្នៃ ដល់បណ្តាម្ចាស់រោងចក្រ និងអ្នកនាំចេញឱ្យយល់ដឹងពីផលប្រយោជន៍នៃគុណភាពជ័រកៅស៊ូ<br>+ ១ឆ្នាំ១៥ដង/១៥ខេត្ត<br>+ ៣០រោងចក្រ ទទួលបានចំណេះដឹងការកែច្នៃ | ១៨.០០០ | ន.កផក និងវសកក |
| | | | x | X | x | X | X | x | x | x | x | x | - ចុះពិនិត្យនិងផ្សព្វផ្សាយ ដល់បណ្តាម្ចាស់រោងចក្រ និងអ្នកនាំចេញឱ្យយល់ដឹងពីផលប្រយោជន៍នៃវិញ្ញាបនបត្របញ្ជាក់គុណភាពជ័រកៅស៊ូ<br>+ ១ឆ្នាំ៣០ដង/១៥ខេត្ត<br>+ ៣០រោងចក្រ ត្រូវបានចុះបញ្ជិកា និងទទួលយកវិញ្ញាបនបត្របញ្ជាក់គុណភាព | ៥៤.០០០ | វសកក |





| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៦.ការពង្រឹងតួនាទីដឹកនាំអគ្គនាយកដ្ឋានកៅស៊ូ និងអភិបាលកិច្ច | - ជាអង្គភាពដឹកនាំដ៏មានថាមភាពដើម្បីឆ្លើយតបចំពោះរាល់តម្រូវការ និងការពេញចិត្តគ្រប់តួអង្គនៃផ្នែកកៅស៊ូ | | | | | | | | | | | - ទទួលបានសេចក្តីព្រាង ច្បាប់ និងច្បាប់ស្តីពីកៅស៊ូ | | |
| | | | X | x | x | | | | | | | | + ប្រជុំក្រុមការងារ តាក់តែងច្បាប់ ១ សប្តាហ៍ ២ដង ១ដង១៥នាក់ | ៨.៦៤០ | ន.រន |
| | | | x | x | x | | | | | | | | + ប្រជុំអន្តរនាយកដ្ឋានអគ្គនាយកដ្ឋានកៅស៊ូដើម្បីកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ៣ខែម្តង ១ដង៣៥នាក់ | ៨៤០ | |
| | | | x | x | x | | | | | | | | + សិក្ខាសាលាកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ១ឆ្នាំ ១ដង, ១៥០នាក់/ ដង | ១១.២៥០ | |
| | | | | | | | | | | | | | + ជួលអ្នកជំនាញផ្នែកច្បាប់ជាតិ និងអន្តរជាតិ | | |
| | | | x | x | x | | | | | | | | ក- អ្នកជំនាញផ្នែកច្បាប់ជាតិ១នាក់/ ៩ខែ/ ឆ្នាំ | ២៧.០០០ | |
| | | | | x | x | | | | | | | | ខ- អ្នកជំនាញផ្នែកច្បាប់អន្តរជាតិ ១នាក់/៦ខែ/ ឆ្នាំ | ២១៦.០០០ | |
| | | | x | x | x | x | x | x | X | x | x | x | - មន្ត្រីទទួលបន្ទុកកៅស៊ូ មានសមត្ថភាព និងជំនាញគ្រប់គ្រាន់សម្រាប់បម្រើការងារ | | |
| | | | | | | | | | | | | | + ធ្វើការបណ្តុះបណ្តាលមន្ត្រី២០នាក់/ ឆ្នាំ | ៥៦.០០០ | |
| | | | | | | | | | | | | | - បោះពុម្ព និងផ្សព្វផ្សាយច្បាប់ស្តីពី កៅស៊ូឱ្យដល់ប្រតិបត្តិករកៅស៊ូ | | |
| | | | | | | x | x | x | | | | | + បោះពុម្ពច្បាប់ស្តីពី កៅស៊ូចំនួន ១.០០០ច្បាប់ | ៤៥.០០០ | |
| | | | | | | x | X | X | x | X | X | X | + ផ្សព្វផ្សាយ១ឆ្នាំ១ខេត្តម្តង/១៥ខេត្ត ក្នុងម្តងមានអ្នកចូលរួម ១០០នាក់ | ១៥៧.៥០០ | ន.រន |
| | | | | | | x | x | X | X | X | X | X | - រៀបចំវេទិកាគាំទ្រគម្រោងអភិវឌ្ឍន៍កៅស៊ូដើម្បីទាក់ទាញរកដៃគូ សហប្រតិបត្តិការក្នុងការគាំទ្រថវិកានិងបច្ចេកទេស: + ក្នុងស្រុក ១ឆ្នាំ២ដង | ៨៤.០០០ | ន.ទសអ |





| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | - ដាក់ភ្នាក់ងារតាមច្រកនាំចេញដើម្បីពិនិត្យការនាំចេញផលិតផលកៅស៊ូ | | |
| | | | | | | x | x | | | | | | + សង់ស្នាក់ការតាមច្រកនាំចេញ ៨ច្រក | ៩៦.០០០ | |
| | | | | | | | | | | | | | + សម្ភារ ឧបករណ៍ និងមធ្យោបាយបម្រើការងារ | ៨៤.០០០ | |
| | | | | | x | x | | | | | | | - ដាក់មន្ត្រី និងសាងសង់ការិយាល័យតាមខេត្តចំនួន១៥ | | |
| | | | | | | | | | | | | | + ៦ម គុណ ៨ម ចំនួន១៥ការិយាល័យ | ៤៣២.០០០៣ | ន.ផហស |
| | | | | | | | | | | | | | + ៨ម គុណ ១២ម ចំនួន១៥ ផ្ទះ | ៣៦០.០០០ | |
| | | | | | | | | | | | | | + សម្ភារការិយាល័យ | ៦០.០០០ | |
| | | | | | | | | | | | | | + ទូរដាក់ឯកសារ | ៦.០០០ | |
| | | | | | | | | | | | | | + តុ កៅអី៥ គុណ ១៥ការិ. | ១៣.៥០០ | |
| | | | | | | | | | | | | | + កុំព្យូទ័រ ព្រីនធ័រ ១គ្រឿង គុណ១៥ | ១០.៥០០ | |
| | | | | | x | x | | | | | | | - ទិញមធ្យោបាយសម្រាប់ការិយាល័យគ្រប់ខេត្តមានកៅស៊ូ | | |
| | | | | | | | | | | | | | + រថយន្ត ១គ្រឿង គុណ១៥ | ៤៥០.០០០ | |
| | | | | | | | | | | | | | + ម៉ូតូ ២គ្រឿង គុណ ១៥ | ៤៥.០០០ | |
| | | | | | | | | | | | | | **សរុបរួម** | **៥.៧៥១.៤៦០** | |

**កំណត់សម្គាល់ ៖**

- ន.ផហស នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ
- ន.ទសអ នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ
- វសកក វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- ន.កផក នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ
- ន.រន នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម
- ន.អក នាយកដ្ឋាន អភិវឌ្ឍកៅស៊ូ








**អគ្គនាយកដ្ឋានកៅស៊ូ**

អាស័យដ្ឋាន : លេខ៤៨ វិថីនារីក្លាហាន
សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ទូរស័ព្ទលេខ :(៨៥៥) ២៣ ៧២២៥៩០
ទូរសារលេខ :(៨៥៥) ២៣ ៧២២៤៩០
អ៊ីមែល :gdr@yahoo.com.kh





**GENERAL DIRECTORATE OF RUBBER**

Address :No.48, Neary Klahan St.,
Sangkat Sras Chak,
Khan Daun Penh, Phnom Penh
Telephone : (855)23 722 590
Fax : (855)23 722 490
Email : gdr@yahoo.com.kh




